# អ្នកនាំសារ
The Messenger

០១

ឆ្នាំទី១ ថ្ងៃទី០១-១៥ កញ្ញា ២០០៧- ច្បាប់អនុញ្ញាតរបស់ក្រសួងព័ត៌មានលេខ ១៨៣ ពមប្រក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ ២០០៧



**មាតិកាសំខាន់ៗ**




**មហាសន្និបាតយុវជនកាតូលិកទាំងបីភូមិភាគ** ទំព័រ ៥



**អង្គការមនុស្សលោកថ្មីគាំពារជនពិការ** ទំព័រ ៩

**ជំងឺរលាកស្រោមខួរក្បាល** ទំព័រ ១០


# ភាសាកូរ៉េកំពុងក្លាយជាទីចាប់អារម្មណ៍



ទំព័រទី១...






## កម្មវិធីវិទ្យុ



**អេម៉ានូអែល** សំឡេងពីព្រះសហគមន៍កាតូលិក !

**ភ្នំពេញ : FM 99.5 Mhz** ម៉ោង ៧:០០-៧:៣០ រាល់យប់ថ្ងៃសៅរ៍ ។

**បាត់ដំបង : FM 91.0 Mhz** ម៉ោង ៧:៣០-៨:០០ រាល់យប់ថ្ងៃសៅរ៍ ។

**កំពង់ធំ : FM 107.3 Mhz** ម៉ោង ៥:៣០-៦:០០ រាល់ល្ងាចថ្ងៃសៅរ៍ ។

**កំពង់ចាម : FM 100.5 Mhz** ម៉ោង ៩:៣០-១០:០០ យប់ថ្ងៃអាទិត្យ ។

**ក្រុងព្រះសីហនុ : FM 100.5 Mhz** ម៉ោង៧:៣០-៨:០០ យប់ថ្ងៃសៅរ៍ ។

# ព្រះរាជជីវប្រវត្តិសង្ខេបរបស់ ព្រះមហាវីរក្សត្រិយ៍ នរោត្តម មុនីនាថ សីហនុ



Photo: L. Sovanna

ព្រះអង្គម្ចាស់ក្សត្រិយ៍ នរោត្តម មុនីនាថ សីហនុ ជាបុត្រីរបស់លោកស្រីពុំ ញៀង និងលោកហ្សង់ ហ្វ្រង់ស្វ័រ អ៊ីហ្ស៊ី Jean-François Izzi ដែលជាជនជាតិអ៊ីតាលីកាត់បារាំង។

ព្រះអង្គម្ចាស់ក្សត្រិយ៍មុនីនាថ នរោត្តម សីហនុ ព្រះនាមដើមប៉ូល ម៉ូនិក អ៊ីហ្ស៊ី Paule Monique Izzi ប្រសូតនៅថ្ងៃទី១៨ មិថុនា ឆ្នាំ១៩៣៦ និងបានរៀបអភិសេកជាមួយនិងព្រះមហាក្សត្រនរោត្តមសីហនុនៅខែមេសា ឆ្នាំ១៩៥២។ ព្រះអង្គម្ចាស់ក្សត្រិយ៍បានសិក្សាថ្នាក់បឋមសិក្សា និងមធ្យមសិក្សាក្នុងប្រទេសកម្ពុជានៅបឋមសិក្សានរោត្តម វិទ្យាល័យស៊ីសុវត្ថិ និងវិទ្យាល័យដេកាត។ ព្រះអង្គម្ចាស់ក្សត្រិយ៍បានធ្វើជាប្រធានកាកបាទក្រហមកម្ពុជារហូតដល់ចុងទសវត្សរ៍ឆ្នាំ១៩៦០ ហើយបច្ចុប្បន្ន ជាប្រធានកិត្តិយសកាកបាទក្រហមកម្ពុជា។ ក្រៅពីភាសាខ្មែរ ព្រះអង្គម្ចាស់ក្សត្រិយ៍អាចនិយាយភាសាបារាំង និងអង់គ្លេសផងដែរ។

នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៩២ : ព្រះអង្គម្ចាស់ក្សត្រិយ៍ត្រូវបានលើកតម្កើងដោយព្រះមហាក្សត្រជាសម្តេចព្រះជាយា។

នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ : ព្រះមហាក្សត្របានសព្វព្រះរាជហឫទ័យលើកតម្កើងសម្តេចព្រះជាយា ជាសម្តេចព្រះមហេសី នរោត្តម មុនីនាថ សីហនុនៃប្រទេសកម្ពុជា។ នៅថ្ងៃទី០២ ខែមករា ឆ្នាំ១៩៩៦ : ព្រះមហាក្សត្របានលើកតម្កើងសម្តេចព្រះមហេសីនរោត្តម មុនីនាថ សីហនុ ជាសម្តេចព្រះរាជអគ្គមហេសី។

សម្តេចព្រះរាជអគ្គមហេសីត្រូវបានប្រទានរង្វាន់ Grand Cross of the Royal Order of Cambodia ដោយព្រះមហាក្សត្រ។

សម្គាល់ : ព្រះអយ្យិកា និងព្រះមាតារបស់ព្រះអង្គម្ចាស់ក្សត្រិយ៍ តែងតែមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយព្រះអង្គម្ចាស់ និងម្ចាស់ក្សត្រិយ៍នរោត្តមសុធារស ព្រមទាំងជាមួយព្រះមហាក្សត្រនរោត្តមសុរាម្រិត និងម្ចាស់ក្សត្រិយ៍យានីស៊ីសុវត្ថិកុសុមៈ។ ព្រះអយ្យិកោ ព្រះអយ្យិកា និងព្រះមាតាបិតារបស់ព្រះមហាក្សត្រ នរោត្តម សីហនុ បានដឹងទំនាក់ទំនងនេះតាំងពីការចាប់កំណើតរបស់ព្រះអង្គម្ចាស់ក្សត្រិយ៍មកម្ល៉េះ។

អ្នកនាំសារ



## ថ្ងៃអាទិត្យទី ២៣ ក្នុងរដូវធម្មតា (ថ្ងៃទី០៩ កញ្ញា ឆ្នាំ២០០៧)

**“បើអ្នកណាមិនលះបង់អ្វីៗទាំងអស់ដែលខ្លួនមានទេ អ្នកនោះមិនអាចធ្វើជាសាវ័ករបស់ខ្ញុំបានឡើយ”**

(លូកា ១៤,២៥-៣៣)

ថ្ងៃនេះ ព្រះយេស៊ូមានព្រះបន្ទូលយ៉ាងតឹងរ៉ឹង គឺអ្នកដែលចង់ធ្វើជាសាវ័ករបស់ព្រះអង្គ ត្រូវលះបង់អ្វីៗ ទាំងអស់! សូម្បីអ្វីដែលយើងស្រឡាញ់យ៉ាងខ្លាំងជាងគេ គឺឪពុកម្តាយប្រពន្ធកូនជាងជីវិតរបស់ខ្លួនទៅទៀត ក៏ត្រូវសុខចិត្តលះបង់ដើម្បីទៅតាមព្រះអង្គដែរ។ ព្រះយេស៊ូបង្ហាញនូវមាគ៌ាដ៏តឹងរ៉ឹងម្យ៉ាង ឆ្ពោះទៅកាន់សេចក្តីសុខសាន្តដ៏ពិតប្រាកដ គឺត្រូវស្រឡាញ់ព្រះអង្គលើសអ្វីៗទាំងអស់ក្នុងលោកនេះ។ តើនរណាខ្លះអាចទទួលព្រះបន្ទូលព្រះយេស៊ូបាន? ព្រះបន្ទូលនេះ គឺពិបាកពេក! ត្រង់នេះ ព្រះយេស៊ូប្រៀនប្រដៅដូចព្រះពុទ្ធជាព្រះបរមគ្រូ គឺព្រះបរមគ្រូប្រៀនប្រដៅឱ្យលះបង់អ្វីទាំងអស់ដើម្បីរកធម៌។

ព្រះយេស៊ូមិនសុំឱ្យយើង លែងស្រឡាញ់ឪពុកម្តាយ ប្រពន្ធ កូន ដូចជា ក្រុមគ្រីស្តបរិស័ទខ្លះនិយាយផ្តេសផ្តាសទេ (ពាក្យអារ៉ាមេអាំង គេធ្លាប់ថែងពាក្យ “ស្អប់” ប៉ុន្តែនេះមានន័យថា “ស្រឡាញ់តិចជាង”) ដូច្នេះត្រូវចាត់ទុកព្រះយេស៊ូគឺជាកំពូលនៃជីវិត យើងស្រឡាញ់ឪពុកម្តាយ ប្រពន្ធ កូន និង ជីវិតខ្លួនយ៉ាងខ្លាំង តែត្រូវស្រឡាញ់ព្រះអង្គរឹតតែខ្លាំងទៅទៀត។ នៅប្រទេសកម្ពុជា ក៏ដូចនៅប្រទេសផ្សេងៗទៀត ជួនកាលក៏មានកើតជម្លោះនៅក្នុងក្រុមគ្រួសារ រវាងឪពុកម្តាយ ឬបងប្អូន។ អ្នករាជការតែងចោទថា យើងជាគ្រីស្តបរិស័ទ ជាអ្នកក្បត់សាសនា ឬក៏ក្បត់ប្រពៃណដូនតា-ល-។ ពេលនោះ ត្រូវនឹកអំពីព្រះបន្ទូលនេះ គឺអ្នកត្រូវស្រឡាញ់ព្រះយេស៊ូខ្លាំងជាងញាតិសន្តានទៅទៀត។ ឪពុកម្តាយបានបញ្ជូនជីវិតឱ្យយើងមែន។ យើងជាកូន គឺត្រូវតែអរគុណ និងគោរពគាត់ យើងមិនមែនកូនអកតញ្ញូ ដូចអ្នកខ្លះចោទទេប៉ុន្តែព្រះយេស៊ូប្រទានព្រះជន្មផ្ទាល់របស់ព្រះអង្គ គឺជាព្រះជន្មរបស់ព្រះបិតា។ នេះគឺប្រសើរជាងអ្វីៗ ដែលមនុស្សយើងស្មាន។



សូមបងប្អូនមានចិត្តក្លាហាន ទោះបីជាមានគេជំទាស់ និងមានបំណងរារាំងផ្លូវរបស់បងប្អូនក៏ដោយចុះ។ សូមបងប្អូនសុខចិត្ត ដើរតាមព្រះយេស៊ូដែលជាកំពូលនៃជីវិតបងប្អូនទាំងអស់គ្នា។

## ថ្ងៃអាទិត្យទី ២៤ ក្នុងរដូវធម្មតា (ថ្ងៃទី១៦ កញ្ញា ឆ្នាំ២០០៧)

**“ព្រះជាម្ចាស់មានអំណរសប្បាយជាខ្លាំង ដោយមានមនុស្សបាប តែម្នាក់ប្រែចិត្តគំនិត”**

(លូកា ១៥,១-៣៥)

ព្រះយេស៊ូមានព្រះបន្ទូលជាប្រស្នាបី អំពីអំណរសប្បាយរបស់មនុស្សម្នាក់ដែលបាត់អ្វីមួយដ៏មានតម្លៃ ហើយរកឃើញវិញ។ ម្នាក់បាត់កូនចៀមមួយក្បាលដែលវង្វេង ហើយរកឃើញវិញ។ ស្ត្រីមេផ្ទះម្នាក់បាត់ប្រាក់ដួងមួយកាក់រកឃើញវិញ។ ឪពុកម្នាក់បាត់កូន និងរកឃើញវិញ។

ព្រះបន្ទូលជាប្រស្នាទាំងបីនេះ បញ្ជាក់អំពីព្រះហឫទ័យស្រឡាញ់របស់ព្រះបិតាដែលស្រឡាញ់មនុស្សហួសពីការស្មាន ឬស្រមៃឃើញរបស់មនុស្ស។ អ្នកបាបក៏ព្រះអង្គស្រឡាញ់ដែរ ហើយរង់ចាំឱ្យគេមករកព្រះអង្គ។ ព្រះបិតាប្រព្រឹត្តតាមរបៀបខុសពីប្រពៃណីខ្មែរ! ប្រសិនបើកូនសុំចែកមតិក ចាយវាយផ្តេសផ្តាស និងវិលមកផ្ទះវិញ តើបងប្អូនជាឪពុកនឹងធ្វើយ៉ាងណា? មុខជាបងប្អូននឹងវាយកូន កាត់កាលកូន ឬវាយជាពុំខាន! ផ្ទុយទៅវិញ សូមមើល! ឪពុកម្នាក់នោះនឹកវាជានិច្ច ទោះបីគាត់ចាស់ជាងកូនក្តី ក៏គាត់រត់ទៅទទួលកូន មិនស្តីបន្ទោស ហើយមានអំណរសប្បាយ ជប់លៀង អញ្ជើញគេឱ្យចូលរួម ដោយមិនខ្មាសគេទេ។ អស្ចារ្យមែន!

ព្រះបន្ទូលជាប្រស្នានេះសម្តែងពីព្រះហឫទ័យស្រឡាញ់ដ៏លើសលប់អស្ចារ្យរបស់ព្រះបិតារកពាក្យថ្លែងមិនបាន។ ព្រះអង្គមិនប្រកាន់បុណ្យបាបមនុស្សទេ។ ព្រះអង្គមានតែព្រះហឫទ័យស្រឡាញ់ប៉ុណ្ណោះ ដ្បិតមនុស្សទាំងអស់ សុទ្ធសឹងជាបុត្រធីតារបស់ព្រះអង្គ។ ជីវិតរបស់មនុស្សយើងម្នាក់ៗ សុទ្ធតែមានតម្លៃ ដោយហេតុនេះហើយ បានជាព្រះអង្គរាប់រកយើងទាំងអស់គ្នាបែបនេះ។



បើដូច្នេះ! យើងមិនត្រូវប្រកាន់អ្នកដទៃទាល់តែសោះថា ជាមនុស្សខូច មនុស្សមិនល្អ អ្នកបាប ឬជាប់វង្សត្រកូលមិនថ្លៃថ្នូរ-ល-។ តែជួនកាលយើងក៏ចង់ឱ្យព្រះសហគមន៍មានសុទ្ធតែជាមនុស្សល្អត្រឹមត្រូវដែរ។ ចូរបងប្អូនយកចិត្តទុកដាក់មានចិត្តស្រឡាញ់ដូចព្រះបិតា...

**សូមថ្លែងអំណរគុណដល់ជំនួយរបស់ក្រុមការងារមណ្ឌលវប្បធម៌កាតូលិកនៅកម្ពុជា!**





## តើមានរូបអ្វីសម្រាប់លេខនេះ...?



ទោះបីជាលោកគឺជាជនពិការមែន ប៉ុន្តែទឹកចិត្តរបស់លោកមិនដែលពិការឡើយ។ លោកខិតខំធ្វើការងារយ៉ាងធ្ងន់ធ្ងរជារៀងរាល់ថ្ងៃដើម្បីចិញ្ចឹមជីវិត។



ភ្ញៀវទេសចរណ៍ចង្អុលទៅកាន់មេដឹកនាំម្នាក់នៃរបបកម្ពុជាប្រជាធិបតេយ្យនៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង។ តាមប្រវត្តិវិទូជាច្រើន ប្រជាជនខ្មែររាប់ម៉ឺននាក់ត្រូវស្លាប់ដោយសារតែការអត់ឃ្លាន និងការសម្លាប់ក្នុងរបបនេះ។



ដោយសារប្រទេសជាតិមានសន្តិភាព ប្រជាជនខ្មែរអាចប្រកបរបរចិញ្ចឹមជីវិតប្រចាំថ្ងៃតាមចំនូលចិត្តរបស់ខ្លួន



របាំគឺជាប្រពៃណីរស់រវើក ដែលកូនខ្មែរគ្រប់រូបត្រូវតែជួយជ្រោមជ្រែង និងលើកតម្កើងតទៅមុខទៀត

Photographed by L. Sovanna





# សូមស្វាគមន៍!



“ហេតុអ្វីបានជាចាំបាច់មានកាសែត ឬទស្សនាវដ្តីបន្ថែមទៀត? ព្រោះមានកាសែត និងទស្សនាវដ្តីច្រើនហើយ! យើងពុំត្រូវការទៀតទេ! នេះគ្រាន់តែជាទស្សនៈរបស់មនុស្សមួយចំនួននៅពេលដែលគេបានឃើញសារព័ត៌មានជាច្រើនត្រូវបានដាក់លក់នៅលើទីផ្សារ។

ការបង្កើតនូវកាសែតថ្មីមួយទៀត គឺជួយពង្រឹងសណ្តាប់ធ្នាប់ក្នុងសង្គមដែលកំពុងអភិវឌ្ឍ និងជាសញ្ញាមួយនៃសេរីភាពសារព័ត៌មានក្នុងប្រទេសកាន់លទ្ធិប្រជាធិបតេយ្យដូចប្រទេសកម្ពុជាយើង។ ការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិកដែលបានបង្កើតព្រឹត្តិបត្រសារព័ត៌មាន “អ្នកនាំសារ” គឺជាការិយាល័យព័ត៌មានរបស់ព្រះសហគមន៍កាតូលិកកម្ពុជា។

ក្នុងឱកាសនេះ យើងខ្ញុំសូមថ្លែងអំណរគុណដល់ក្រសួងព័ត៌មាន ដែលបានអនុញ្ញាតឱ្យព្រឹត្តិបត្រនេះចុះផ្សាយក្នុង១ខែពីរដង ចែកជូនដល់សាធារណជន។ គោលដៅសំខាន់របស់យើង គឺចែករំលែកយោបល់ និងគំនិតតាមទស្សនៈគ្រីស្តសាសនាចំពោះរឿងរ៉ាវក្នុងសង្គមទូទៅ។ ព្រះសហគមន៍កាតូលិកមានវត្តមាននៅប្រទេសកម្ពុជាតាំងពីសតវត្សទី១៦។ ព្រះសហគមន៍តែងតែចាប់អារម្មណ៍អំពីប្រជាជនខ្មែរនៅក្នុងសង្គមគ្រប់រូបភាព ជាពិសេសទាក់ទងនឹងការអប់រំ ការអភិវឌ្ឍជនបទ សីលធម៌សង្គម និងបរិស្ថាន។ ព្រឹត្តបត្រ “អ្នកនាំសារ” ចង់ធ្វើការចែករំលែកព័ត៌មានល្អៗ ដើម្បីជួយដល់សង្គមជាតិទាំងមូល។

តាមបទពិសោធន៍នៃព្រះសហគមន៍កាតូលិក ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានមានសារៈសំខាន់ណាស់ក្នុងសង្គម។ យើងគួរតែប្រើដោយលក្ខណៈត្រឹមត្រូវ។ អតីតសម្តេចប៉ាប យ៉ូហាន ប៉ូល ទី២ អះអាងថា : “ការវិវឌ្ឍនៃបច្ចេកវិទ្យាដ៏លឿនសម្បើមក្នុងប្រព័ន្ធព័ត៌មាន ជាសញ្ញាមួយដ៏ល្អក្នុងការចូលរួមអភិវឌ្ឍក្នុងសង្គម។” សព្វថ្ងៃនេះនៅប្រទេសកម្ពុជា យើងក៏ឃើញការវិវឌ្ឍនេះរីកចម្រើនយ៉ាងឆាប់រហ័សដែរ។ នេះគឺជាឱកាសដ៏ល្អមួយដើម្បីរិះគិតអំពីរបៀបដែលយើងអាចជួយយុវជន-នារី ចេះប្រើប្រាស់នូវព័ត៌មានទាំងអស់នោះដោយត្រឹមត្រូវ។ “អ្នកនាំសារ” ចង់ធ្វើជាអ្នកបម្រើដើម្បីបំពេញបេសកកម្មនេះ។ សូមអរគុណ!

**លោកឪពុក អូមែរ ហ្ស៊ីរ៉ាល់ដូ**

# លោកបូជាចារ្យអែន រីកូ : “ពួកគេបានផ្តល់សេចក្តីស្រឡាញ់ចំពោះខ្ញុំយ៉ាងកក់ក្តៅ”


Photo: P. Samphy

**លោកអែនរីកូ ជាអ្នកគ្រប់គ្រងមណ្ឌលនិស្សិតកាតូលិកកម្ពុជា ជាង៤ឆ្នាំមកហើយ។ ថ្មីៗនេះ លោកបានចាកចេញពីប្រទេសកម្ពុជា ដើម្បីទៅរៀនបន្តនៅប្រទេសអ៊ីតាលី។ នេះជាបទសម្ភាសន៍ជាមួយលោក :**

---

**អ្នកនាំសារ : តើលោកយល់យ៉ាងណាដែរចំពោះរយៈពេល៤ឆ្នាំ ដែលលោករស់នៅជាមួយនិស្សិតខ្មែរ ?**

**លោកអែនរីកូ :** ខ្ញុំពិបាកឆ្លើយ ហើយអារម្មណ៍របស់ខ្ញុំក៏ពិបាកនឹងទទួល ដោយសារតែសេចក្តីស្រឡាញ់យ៉ាងជ្រាលជ្រៅពីពួកគេសម្រាប់ខ្ញុំ។ ខ្ញុំអាចនិយាយបានថា ជាង ៤ឆ្នាំ ដែលខ្ញុំរស់នៅជាមួយគេ គឺជាបទពិសោធន៍យ៉ាងជ្រាលជ្រៅក្នុងជីវិតរបស់ខ្ញុំ ដោយសារតែរបៀបដែលយើងបានរស់នៅជាមួយគ្នា។ យើងចែករំលែកនូវបទពិសោធន៍ មិនគ្រាន់តែការសិក្សាទេ ប៉ុន្តែ ក្នុងជីវិតយើងផ្ទាល់ទាំងអតីតកាល បច្ចុប្បន្ន និងអនាគតដែរ។ រាល់ថ្ងៃ យើងរៀនជាមួយគ្នា រស់នៅជាមួយគ្នា ដូចជាឪពុក និងកូនបង្កើតអ៊ីចឹង។ អ្វីដែលធ្វើឱ្យខ្ញុំចាំមិនភ្លេច គឺនិស្សិតបានទទួលខ្ញុំយ៉ាងពិតប្រាកដមែន ទោះបីជាខ្ញុំនិយាយខ្មែរមិនច្បាស់ និងគេស្តាប់មិនសូវបានក្តី។ ប៉ុន្តែគេទទួលខ្ញុំដែលជាជនបរទេសម្នាក់ជួយខ្ញុំ និងបង្រៀនខ្ញុំច្រើន។ ខ្ញុំត្រូវតែអរគុណគេ។ យើងក៏ធ្លាប់ឈ្លោះគ្នាច្រើន តែក្នុងនោះ យើងមានក្តីស្រឡាញ់ច្រើនជាង។

**អ្នកនាំសារ : តើលោកយល់ដូចម្តេចដែរចំពោះសមត្ថភាពរបស់និស្សិតកាតូលិកកម្ពុជា ?**

**លោកអែនរីកូ :** ខ្ញុំឃើញថា សមត្ថភាពផ្ទាល់ខ្លួនពួកគេមានគ្រប់គ្រាន់។ តែចំពោះមធ្យោបាយ ដែលគេទទួលបានតាមសាលា ឬសង្គមនៅខ្វះខាតច្រើន។ ទីមួយ គឺបទពិសោធន៍ជាក់ស្តែង។ ឧទាហរណ៍និស្សិតដែលរៀនសេដ្ឋកិច្ច ឯកសារដែលគេមាន ជាឯកសារនិយាយអំពីសេដ្ឋកិច្ចអាមេរិក ឬអឺរ៉ុបដែលមានខ្នាតធំខុសពីសេដ្ឋកិច្ចកម្ពុជា ឬអាស៊ីអាគ្នេយ៍ទាំងស្រុង។ ដូច្នេះនៅពេលដែលគេបញ្ចប់ការសិក្សា គឺគេពិបាកយកមកអនុវត្តនូវអ្វីដែលគេបានរៀន នៅទីផ្សារក្នុងស្រុកណាស់។ ទីពីរ ឧបករណ៍ដែលគេប្រើតាមសាលាមានខ្វះខាតច្រើន។ និស្សិតត្រូវបកប្រែឯកសាររបស់បរទេសទាំងស្រុង។

**អ្នកនាំសារ : តើពួកគេអាចមានសមត្ថភាពដើម្បីប្រកួតប្រជែងជាមួយនិស្សិតនៅក្រៅប្រទេសបានដែរឬទេ ?**

**លោកអែនរីកូ :** ដូចដែលខ្ញុំបានលើកមកពីខាងដើមរួចហើយ គឺពួកគេមានការព្យាយាមខិតខំរៀនសូត្រខ្លាំងណាស់។ ប៉ុន្តែដូចខ្ញុំរៀននៅក្នុងប្រទេសមួយដែលមានឯកសារគ្រប់គ្រាន់ជាភាសារបស់ខ្ញុំ វានៅពិបាក។ ប៉ុន្តែវាស្រួលជាងបន្តិចដោយពុំចាំបាច់បកប្រែភាសា។ នៅទីនេះវិញ ឯកសារភាគច្រើនជាភាសាបរទេស ដូច្នេះវាជាការលំបាកចំពោះពួកគេ។ តែខ្ញុំសូមសរសើរចំពោះពួកគេព្រោះគេនៅតែខំប្រឹងរៀនសូត្រមែនទែន។

**អ្នកនាំសារ : តើលោកមានអ្វីផ្តាំផ្ញើដល់និស្សិតកាតូលិកក៏ដូចជាកូនខ្មែរទាំងអស់ដែរឬទេ ?**

**លោកអែនរីកូ :** ខ្ញុំចង់ផ្តាំផ្ញើពួកគេ សូមជឿជាក់លើខ្លួនឯង។ ទោះបីជាការងារតិចតួចក្តី យើងត្រូវដាក់គោលដៅឱ្យច្បាស់លាស់។ យើងឃើញថា ការរស់ក្នុងសង្គមសព្វថ្ងៃ មានការពិបាកពិតប្រាកដមែន។ នៅកន្លែងធ្វើការ យើងមិនសូវជជែកគ្នា ឬគំនិតយើងក៏មិនត្រូវគ្នា។ បើយើងធ្វើការនៅក្នុងក្រុមហ៊ុន យើងពុំសូវមានពេលវេលាជាមួយគ្នា។ ប៉ុន្តែអ្វីដែលសំខាន់ យើងត្រូវតែដឹងថា សង្គមយើងជាអ្នក ដាក់គោលដៅ និងរៀបចំដ៏ពិតប្រាកដមែន ដូច្នេះវាមានន័យថា យើងមាននូវអំណាចម្យ៉ាងនៅក្នុងសង្គម ជាពិសេសគំនិតរបស់យើង។

**ហ៊ូ សុខធារី**

## ជំនួបយុវជនសាលេស៊ានអាស៊ីបូព៌ាជាលើកដំបូង

**កាលពីថ្ងៃទី១០-១៣ សីហា ២០០៧កន្លងទៅ នៅប្រទេសហ្វីលីពីន មានជំនួបយុវជនសាឡេស៊ានលើកដំបូង ដែលមានការចូលរួមពី ១៣ប្រទេស មាន ចិន ឥណ្ឌូនេស៊ី កោះតៃវ៉ាន់ ម៉ាការ ហុងកុង ទីម័រខាងកើត ភូមា កម្ពុជា ថៃ វៀតណាម កូរ៉េ ជប៉ុន និងហ្វីលីពីន ដែលសរុបមានអ្នកចូលរួមចំនួនជាង ៣០០នាក់។ គោលបំណងគឺដើម្បីឱ្យយុវជនទាំងនោះ : រកឃើញអំពីតម្លៃជាយុវជននៅទ្វីបអាស៊ី រំលែកបទពិសោធន៍ មានបទពិសោធន៍អំពីការបម្រើអ្នកដទៃដោយស្ម័គ្រចិត្ត និងដោយការប្តេជ្ញាចិត្ត និងលើកតម្កើងជីវិតក្នុងភាពរីករាយ និងក្នុងជំនឿ-ល-។ កែវ កញ្ញា**


Photo: K. Kangha
យុវនារីជប៉ុនសម្តែងកាយតាមបទចម្រៀងក្នុងអង្គជំនួប

## លោកតូម៉ាស នូហ្សេបង្ហាញសក្ខីភាពអំពីប្រទេសខ្មែរ និងដំណើរផ្សងព្រេងដ៏ធំមួយ


Photo: P. Samphy

លោកតូម៉ាស នូហ្សេ គឺជាជនជាតិបារាំង។ លោកជាអ្នកស្ម័គ្រចិត្ត ធ្វើគណនេយ្យករនៅគេហដ្ឋានរបស់លោក អេមីល ដេតម្បូ អភិបាលភូមិភាគភ្នំពេញ។ លោកមកប្រទេសកម្ពុជាតាំងពីថ្ងៃទី១៥ កញ្ញា ឆ្នាំ២០០៥ តាមរយៈក្រុមសាសនទូតបេសកកម្មក្រៅប្រទេសនៃទីក្រុងប៉ារីស។ នៅអំឡុងពាក់កណ្តាលខែសីហាកន្លងទៅនេះ លោកបានបញ្ចប់បេសកកម្មរបស់លោក។ លោកបានរៀបរាប់ខ្លះៗអំពីបទពិសោធន៍របស់លោកនៅកម្ពុជា និងគម្រោងការធ្វើដំណើរផ្សងព្រេងមួយ បន្ទាប់ពីចាកចេញពីប្រទេសកម្ពុជា ឱ្យដឹងយ៉ាងនេះថា :

ពីរឆ្នាំដូចជាខ្លី ប៉ុន្តែខ្ញុំយល់ថា ខ្ញុំមានទំនាក់ទំនងយ៉ាងល្អជាមួយនឹងជនជាតិខ្មែរ។ ប្រជាជនខ្មែរ គឺមានចរិតសុភាពរាបសាក្នុងរបៀបជាទូទៅ។ ទាំងអស់គ្នាចូលចិត្តញញឹម មានទំនាក់ទំនងបើកចំហ និងទន់ភ្លន់។ ចំពោះបរិយាកាសរស់នៅវិញ ក្រៅពីបញ្ហាចោរកម្មតិចតួច និងគ្រោះថ្នាក់ចរាចរណ៍ខ្លះៗ គ្មានអ្វីធំដុំទេ។ ខ្ញុំអាចនិយាយថា ជីវិតងាយស្រួលសម្រាប់ខ្ញុំជាងនៅស្រុកបារាំងផង ពីព្រោះការចំណាយលើជីវភាព មានតម្លៃថោកដែលនៅស្រុកបារាំងអ្វីៗ ក៏ថ្លៃ។

សម្រាប់ខ្ញុំ ប្រទេសកម្ពុជាជាប្រទេសដ៏ល្អមួយ ដែលមានអង្គរវត្តដ៏អស្ចារ្យ មានស្ទឹង ព្រៃ សមុទ្រ ទេសភាពចំរុះ និងជនជាតិដែលមានភាពរាក់ទាក់-ល-។ ចំណែកព្រះសហគមន៍ មានសកម្មភាពរស់រវើក និងរាយប៉ាយពេញផ្ទៃប្រទេស។ ទាំងនេះ គឺជាលក្ខណៈវិនិច្ឆ័យ ដែលខ្ញុំនឹងរៀបរាប់ប្រាប់ជនបរទេស ហើយនិងជំរុញឱ្យពួកគេមកទស្សនាប្រទេសកម្ពុជា។

បន្ទាប់ពីប្រទេសកម្ពុជានេះ ខ្ញុំនឹងធ្វើដំណើរផ្សងព្រេងមួយដោយថ្មើរជើងឆ្លងកាត់ទ្វីបអាស៊ី។ ខ្ញុំមានបំណងចង់ធ្វើជាសាក្សីដោយក្រសែភ្នែកនិងសំណេរ... ស្វែងយល់ពីវប្បធម៌ និងសាសនាសំខាន់ៗនៅទ្វីបនេះ ដូចជា ព្រះពុទ្ធសាសនា លទ្ធិខុងជឺនៅស្រុកចិន សាសនាហិណ្ឌូនៅឥណ្ឌា និងឥស្លាមនៅមជ្ឈិមបូព៌ាជាដើម។

**ជាត សំភី**







# មហាសន្និបាតយុវជនទាំងបីភូមិភាគ


Photo: S. Philong

**“ចូរមកតាមខ្ញុំ អ្នកនឹងឃើញ” នេះជាសំឡេងផុសចេញពីការសម្តែងកាយវិការនៅក្នុងមហាសន្និបាតយុវជនកាតូលិកទាំងបីភូមិភាគ ក្រោមប្រធានបទ : “ការនិទានពីជីវិតព្រះយេស៊ូក្នុងការរស់នៅរបស់យើងខ្ញុំ”។**

មហាសន្និបាតនេះប្រព្រឹត្តទៅអស់រយៈពេល ៣ ថ្ងៃ គឺចាប់ពីថ្ងៃទី២១-២៣ សីហា នៅក្នុងបរិវេណសាលាដុនបូស្កូទឹកថ្លា ដែលមានការចូលរួមពីលោកបូជាចារ្យ បងស្រី និងយុវជនសរុបប្រមាណជាង ៣៥០នាក់។

លោកបូជាចារ្យប៉េដ្រូ ហ្គោមេ ជនជាតិកូឡុំប៊ី ទទួលបន្ទុកនៅព្រះសហគមន៍បាត់ដំបង បានឱ្យដឹងពីគោលបំណងនៃអង្គសន្និបាតនេះ គឺយើងចង់បង្កើតទំនាក់ទំនង រវាងយុវជន និងយុវជន ទាំងបីភូមិភាគ ឱ្យពួកគេយល់ថា យើងជាព្រះសហគមន៍តែមួយ ហើយអ្វីដែលសំខាន់នោះ គឺព្រះសហគមន៍ចង់ឱ្យយុវជនទទួលស្គាល់ថា ក្នុងខ្លួនរបស់ពួកគេមានវត្តមានរបស់ព្រះយេស៊ូគ្រីស្ត ហើយទ្រង់រួមដំណើរក្នុងជីវិតប្រចាំថ្ងៃជាមួយពួកគេ។

ជាមួយគ្នានេះដែរ គឺយើងចង់ឱ្យយុវជនហ៊ានធ្វើជាសាក្សីនៃក្តីស្រឡាញ់របស់ព្រះយេស៊ូចំពោះអ្នកដទៃនៅជុំវិញខ្លួន។

ស្របជាមួយគ្នានេះដែរ លោកបូជាចារ្យស្រ៊ីប្រាមុង វិរជ័យ សាសនទូតពីប្រទេសថៃ និងជាអ្នកទទួលខុសត្រូវនៅព្រះសហគមន៍ក្រុងព្រះសីហនុ មានប្រសាសន៍ថា ការនិទានពីជីវិតព្រះយេស៊ូ ដូចជាយើងម្នាក់ជាយុវជន និងធ្វើជាសាក្សីថា ព្រះយេស៊ូនៅជាមួយយើងជារៀងរាល់ថ្ងៃ ដែលពេលខ្លះយើងមិនដឹងថាព្រះយេស៊ូគង់នៅជាមួយយើងទេ។

យុវជនមួយចំនួនដើរផ្លូវខុស ដោយសារគេយល់ថា មិនមាននរណាស្រលាញ់គេ មិនមាននរណាចាប់អារម្មណ៍លើគេ។ ប៉ុន្តែគេមិនដឹងថា ព្រះយេស៊ូគង់នៅជាមួយគេឡើយ។ ហេតុដូចនេះបើគេដឹងថា ព្រះជាម្ចាស់ស្រលាញ់ពួកគេ នោះគេនឹងយល់ថា ជីវិតមានតម្លៃ។ គេនឹងចង់ចែកអ្វីដែលមានតម្លៃនៅក្នុងជីវិតរបស់គេទៅឱ្យអ្នកដទៃ។

មហាសន្និបាតនេះធ្វើជាលើកទី៤ហើយ ដែលព្រះសហគមន៍រៀបចំឡើងសម្រាប់យុវជនទាំងបីភូមិភាគ មានភូមិភាគបាត់ដំបង ភូមិភាគកំពង់ចាម និងភូមិភាគភ្នំពេញ។

ក្នុងភាពសប្បាយរីករាយជាមួយបទភ្លេង និងចម្រៀង យុវជនហែម វិសាលអាយុ ២៥ឆ្នាំ ពីព្រះសហគមន៍ក្រុងព្រះសីហនុ បាននិយាយថា : “ខ្ញុំចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើអង្គសន្និបាតនេះ ព្រោះវាជួយដល់យុវជនជាច្រើនឱ្យរិះគិតរួមគ្នា ចែករំលែកបទពិសោធន៍អំពីជំនឿរបស់ខ្លួន និងផ្តល់សក្ខីភាពអំពីព្រះយេស៊ូដែលគង់នៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ។”

ចំណែកលោកធីម ធន់ អាយុ៣១ឆ្នាំ មកពីព្រះសហគមន៍កាតូលិកសៀមរាប បាននិយាយថា នេះជាកម្មវិធីមួយសម្រាប់លើកកម្ពស់យុវជន និងសម្រាប់ឱ្យយុវជនចេះស្គាល់គ្នាទៅវិញទៅមក និងមានសេចក្តីស្រលាញ់ចំពោះគ្នា។ លោកធន់បានបញ្ជាក់បន្ថែមលើប្រធានបទនេះថា : “អ្វីដែលខ្ញុំចង់បង្ហាញអំពីព្រះយេស៊ូដល់អ្នកដទៃនោះ គឺខ្ញុំជាអ្នកបម្រើព្រះយេស៊ូ និងព្រះសហគមន៍។ ខ្ញុំមានបេសកកម្មមួយ គឺថាខ្ញុំធ្វើអធិដ្ឋាន ចូលអភិបូជា ចូលរួមសកម្មភាពជាមួយអ្នកក្រីក្រនៅក្នុងព្រះសហគមន៍ និងសង្គមផងដែរ។”

មុនពេលអង្គសន្និបាតយុវជនត្រូវបានបញ្ចប់ យុវជនទាំងអស់បានមូលគំនិតគ្នាយកការប្តេជ្ញាចិត្តរួមមួយ គឺយកព្រះយេស៊ូជាគំរូ និងជាទីពឹងក្នុងការរស់នៅប្រចាំថ្ងៃ និងហ៊ានបង្ហាញថា ខ្លួនជាគ្រីស្តបរិស័ទកាតូលិក និងជួយណែនាំអ្នកដែលមិនស្គាល់ព្រះយេស៊ូដោយផ្សាយពីសេចក្តីស្រលាញ់ និងការបម្រើបងប្អូនក្រីក្រ អ្នកជំងឺ ចាស់ជរា និងក្មេងកំព្រាជាដើម។

**កញ្ញា និងសុខជុំ**


Photo: S. Philong
គ្រីស្តបរិស័ទដែលពោរពេញដោយជំនឿក្នុងអង្គសន្និបាត


Photo: L. Sovanna

## ច្បាប់ ! ចរាចរណ៍ផ្លូវគោក

**សេដ្ឋកិច្ចសង្គមមានការរីកឡូតទៅមុខ ចំនួនប្រជាជន និងយានយន្តប្រើប្រាស់ផ្លូវថ្នល់កាន់តែកើនមិនឈប់ឈរនោះ ធ្វើឱ្យចរាចរណ៍ចោទជាបញ្ហាប្រឈមដ៏ធ្ងន់ធ្ងរ និងធ្វើឱ្យប្រជាជនស្លាប់ និងពិការជារៀងរាល់ថ្ងៃ។ ដើម្បីចូលរួមចំណែកកាត់បន្ថយគ្រោះថ្នាក់ អ្នកនាំសារ សូមចុះផ្សាយច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកនៃព្រះរាជាណាចក្រកម្ពុជាដូចតទៅ :**

### ជំពូកទី ១

### បទប្បញ្ញត្តិទូទៅ

មាត្រា ១.

ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកនេះមានវិសាលភាពគ្របដណ្តប់រាល់ការធ្វើចរាចរណ៍លើផ្លូវថ្នល់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

មាត្រា ២.

ច្បាប់នេះមានគោលបំណង :

-រក្សាសណ្តាប់ធ្នាប់ សុវត្ថិភាពក្នុងការធ្វើចរាចរណ៍នៅលើផ្លូវថ្នល់ ដែលបើកឱ្យធ្វើចរាចរណ៍ជាសាធារណៈទូទាំងព្រះរាជាណាចក្រកម្ពុជា

-ការពារអាយុជីវិតមនុស្ស សត្វ និងការពារបរិស្ថាន

-ទប់ស្កាត់ការប៉ះពាល់សុខភាពមនុស្ស និងការខូចខាតទ្រព្យសម្បត្តិរដ្ឋ និងឯកជន

-ទប់ស្កាត់ការប្រព្រឹត្តបទល្មើស ដែលបណ្តាលមកពីការប្រើប្រាស់ផ្លូវថ្នល់ ។

មាត្រា ៣.

អ្នកប្រើប្រាស់ផ្លូវថ្នល់ ត្រូវគោរពឱ្យបានត្រឹមត្រូវតាមបទប្បញ្ញត្តិ ដែលមានចែងក្នុងច្បាប់នេះ ។

មាត្រា ៤.

ការបើកបរយានជំនិះគ្រប់ប្រភេទក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវប្រកាន់ស្តាំជានិច្ច។

សូមតទៅលេខក្រោយ...

**ការសិក្សាជាសកម្មភាពមួយដ៏សំខាន់សម្រាប់ប្រជាពលរដ្ឋខ្មែរ ជាពិសេសសម្រាប់យុវជនយុវនារីខ្មែរ។ នេះគឺជាជំហានទីមួយក្នុងការអភិវឌ្ឍប្រទេស និងជាពិសេស គឺការអភិវឌ្ឍខ្លួនឯង ឱ្យក្លាយជាមនុស្សមួយរូបដែលពោរពេញទៅដោយភាពវាងវៃ និងចេះដឹងនៅក្នុងសង្គម។**

**ជាមួយនេះដែរ ការសិក្សា ភាសាទី២ ក៏កំពុងតែមានភាពពុះកញ្ជ្រោលយ៉ាងខ្លាំងក្លាគួរឱ្យភ្ញាក់ផ្អើលផងដែរ ដែលគេឃើញមានដូចជាភាសាអង់គ្លេស ភាសាជប៉ុន និងភាសាកូរ៉េជាដើម។ ប៉ុន្តែយើងសង្កេតឃើញថា ប៉ុន្មានឆ្នាំនេះ ភាពជ្រួលជ្រើមក្នុងការសិក្សាភាសាកូរ៉េកំពុងបានរីកដុះដាលយ៉ាងគំហុកដោយឃើញមានផុសឡើងនូវសាលា និងមជ្ឈមណ្ឌលឯកជនសិក្សាភាសាកូរ៉េជាច្រើន។ មានសិស្ស-និស្សិតខ្មែររាប់រយនាក់កំពុងមមាញឹកក្នុងការសិក្សាភាសាកូរ៉េ។ តើហេតុអ្វីបានយុវជនងាកមកចាប់អារម្មណ៍សិក្សាភាសាកូរ៉េ? តើពួកគេរៀនគឺដើម្បីតែទីផ្សារការងារក្រៅប្រទេសឬមួយយ៉ាងណា ?**



នៅក្នុងថ្នាក់រៀនភាសាកូរ៉េ យុវជន យុវនារី កំពុងតែត្រងត្រាប់ស្តាប់គ្រូពន្យល់ដោយយកចិត្តទុកដាក់ ពីព្រោះអ្នកទាំងអស់សង្ឃឹមមានការងារល្អមួយធ្វើនៅប្រទេសកូរ៉េ

Photo: L. Samphors

# ភាសាកូរ៉េ កំពុងក្លាយជាទីចាប់អារម្មណ៍



Photo: L. Samphors

**សាលាភាសាកូរ៉េកំពុងតែរីកដុះដាលយ៉ាងខ្លាំង ដូចកាលចាប់ផ្តើមនៃសាលាឯកជនភាសាអង់គ្លេសកាលពីទសវត្សមុនដែរ។ សាធារណរដ្ឋកូរ៉េអាចឱ្យពលករខ្មែរទៅធ្វើការនៅប្រទេសគេបាន ល្គឹកណាពលករនោះចេះភាសាគេដែរ។**

នៅលើពិភពលោករបស់យើងសព្វថ្ងៃនេះ មានការវិវឌ្ឍកាន់តែរីកចម្រើនឡើង ឥតឈប់ឈរ ទាំងនៅលើផ្នែកសេដ្ឋកិច្ច នយោបាយ បច្ចេកវិទ្យា វិស័យទេសចរណ៍ ឬក៏ដូចជាវិស័យទំនាក់ទំនងការទូតរវាងប្រទេសនានា-ល-។ ទន្ទឹមនឹងការរីកចម្រើនទាំងនេះផងដែរសម្រាប់ប្រទេសកម្ពុជាសព្វថ្ងៃ កំពុងមានការរីកចម្រើនយ៉ាងខ្លាំងលើវិស័យការបរទេស និងចំណងការទូតជាមួយប្រទេសផ្សេងៗ។ ហេតុនេះហើយទើបការសិក្សាភាសាបរទេស គឺមានសារៈសំខាន់យ៉ាងក្រៃលែង ពីព្រោះវាគឺជាសញ្ញាណមួយនៃការប្រាស្រ័យទាក់ទងដែលមិនអាចខ្វះបាននៅក្នុងសង្គម។

យើងដឹងហើយថា នៅប៉ុន្មានឆ្នាំមុន សិស្ស-និស្សិត ឬប្រជាពលរដ្ឋខ្មែរភាគច្រើនមានចំណង់រៀនភាសាអង់គ្លេស ឬភាសាបារាំង ប៉ុន្តែក្រោយមក ក្រៅពីភាសាអង់គ្លេសដែលជាភាសាមួយត្រូវបានប្រើប្រាស់ពេញទូទាំងពិភពលោក បច្ចុប្បន្ននេះមានសិស្ស-និស្សិត និងប្រជាពលរដ្ឋខ្មែរជាច្រើន កំពុងតែត្រូវទទួលបាននូវការទាក់ទាញឱ្យមានចំណាប់អារម្មណ៍យ៉ាងខ្លាំងទៅលើការសិក្សាភាសាកូរ៉េ។

ជាក់ស្តែងសព្វថ្ងៃ យើងសង្កេតឃើញមានការកើនឡើងជាលំដាប់នូវចំនួនសាលាសិក្សាភាសាកូរ៉េជាច្រើនទាំងនៅរាជធានីភ្នំពេញ ក៏ដូចជានៅតាមបណ្តាខេត្តផ្សេងៗទៀតផងដែរ។

**តើមូលហេតុអ្វីបានជាប្រជាពលរដ្ឋមានចំណាប់អារម្មណ៍លើការសិក្សាភាសាកូរ៉េ ?**

ទន្ទឹមនឹងសកម្មភាពនៃការបោះទុនវិនិយោគរបស់ជនជាតិកូរ៉េនៅក្នុងប្រទេសកម្ពុជានៅលើវិស័យសំខាន់ៗជាច្រើន សាលារៀន ឬក៏មជ្ឈមណ្ឌលបង្រៀនភាសាកូរ៉េត្រូវបានបង្កើតឡើងជាច្រើនកន្លែងផងដែរ ដើម្បីផ្តល់សេវាអប់រំភាសានេះទៅដល់ប្រជាពលរដ្ឋកម្ពុជាដែលចង់ទៅធ្វើការងារនៅប្រទេសកូរ៉េ ឬធ្វើការងារដែលទាក់ទងប្រើប្រាស់ភាសាកូរ៉េនេះនៅក្នុងប្រទេស។ តួយ៉ាងភាសាកូរ៉េក៏នឹងអាចប្រើប្រាស់បានយ៉ាងទំលំទូលាយសម្រាប់វិស័យទេសចរដែលកំពុងតែមានការរីកចម្រើនជារៀងរាល់ឆ្នាំផងដែរ។

លោក ទី ណារ៉ា ជាគ្រូបង្រៀនភាសាកូរ៉េ និងជាអតីតពលករខ្មែរដែលធ្លាប់ទៅធ្វើការនៅប្រទេសកូរ៉េ មានប្រសាសន៍ថា: "កាលពីពេលមុន មិនសូវមានប្រជាពលរដ្ឋខ្មែរ ដែលចាប់អារម្មណ៍ទៅលើការសិក្សាភាសាកូរ៉េទេ គឺដោយសារភាសានេះ មិនទាន់មានតម្រូវការដូចសព្វថ្ងៃ។" លោកគ្រូរូបនោះ បន្ថែមទៀតដែរថា ប៉ុន្តែឥឡូវនេះ ការសិក្សាភាសាកូរ៉េភាគច្រើន គឺអ្នកសិក្សាមានគោលបំណងដើម្បីទៅបម្រើការងារនៅប្រទេសកូរ៉េ។

ក្រោយពេលសម្រាកពីការបង្រៀន អ្នកនាង ហម សុភារី ដែលជាគ្រូបង្រៀនភាសាកូរ៉េ នៅឯសាលាហ្វឹកហ្វឺនភាសាកូរ៉េ អ៊ី ភី អេស មានប្រសាសន៍ឱ្យដឹងថា : "និយាយទៅ! ចំណង់ចង់សិក្សាភាសាកូរ៉េបណ្តាលមកពីកត្តាពីរ។ កត្តាទី១ ដោយសារតែអ្នកសិក្សាមួយចំនួនគឺមានគោលដៅរបស់ពួកគេ ជាពិសេសគឺមានបំណងចង់ទៅធ្វើការនៅប្រទេសកូរ៉េ និងកត្តាទី២ អ្នកមួយចំនួនទៀតរៀនដើម្បីចូលធ្វើការជាមួយសហគ្រាស ឬក្រុមហ៊ុនផ្សេងៗរបស់កូរ៉េនៅក្នុងស្រុកខ្មែរយើង។" អ្នកគ្រូក៏បន្តទៀតដែរថា ប៉ុន្តែរវាងកត្តាទាំងពីរ កំណើនសិក្សាភាសាកូរ៉េសម្រាប់ក្លាយខ្លួនជាពលករទៅធ្វើការនៅប្រទេសកូរ៉េមានកំណើនឡើងខ្លាំងជាងការសិក្សាដើម្បីស្វែងរកការងារនៅក្នុងប្រទេស។ ទោះជាយ៉ាងណាក្តី ការសិក្សាភាសាកូរ៉េត្រូវទាមទារឱ្យមានការអត់ធ្មត់ និងការតស៊ូពីសិស្សម្នាក់ៗ ដើម្បីសម្រេចបាននូវជោគជ័យ។ ហេតុនេះហើយ ទើបមិនមែនមានន័យថា ឱ្យតែនរណាក៏ដោយ ដែលចង់ទៅធ្វើការនៅប្រទេសកូរ៉េ ចេះតែអាចទៅបាននោះទេ ឬមួយឱ្យតែចេះភាសាកូរ៉េហើយ អាចទៅធ្វើការនៅប្រទេសកូរ៉េបាននោះដែរ ព្រោះថាដើម្បីអាចទៅធ្វើការនៅកូរ៉េ សព្វថ្ងៃនេះ ត្រូវឆ្លងកាត់ការប្រឡងជាច្រើនដំណាក់កាលណាស់ ប៉ុន្តែជាដំបូងត្រូវមានការធ្វើតេស្តជាភាសាកូរ៉េ ជាមុនសិនទើបអាចដាក់ពាក្យរកការងារធ្វើនៅកូរ៉េបាន។

ចំណែកលោកគ្រូទី ណារ៉ា ក៏មានប្រសាសន៍ឱ្យដឹងអំពីសារៈសំខាន់នៃភាសាកូរ៉េថា ការសិក្សាភាសាកូរ៉េមានប្រយោជន៍ច្រើនណាស់។ បើយើងចេះកូរ៉េ យើងអាចដាក់ពាក្យរកការងារធ្វើនៅប្រទេសគេបាន។ម្យ៉ាងវិញទៀត យើងក៏អាចមានលទ្ធភាពរកការងារធ្វើនៅក្រុមហ៊ុនកូរ៉េជាច្រើន ដែលកំពុងត្រូវបានបង្កើត នៅក្នុងស្រុកខ្មែរផ្ទាល់តែម្តង។ "ឆ្លងកាត់តាមបទពិសោធន៍របស់ខ្ញុំ ដែលធ្លាប់បានទៅធ្វើការនៅប្រទេសកូរ៉េ។ ខ្ញុំមើលឃើញថា គឺមានជនជាតិកូរ៉េច្រើននាក់ណាស់ ដែលមានបំណងចង់មករកស៊ី និងបោះវិនិយោគទុននៅស្រុកខ្មែរ។" លោក ទី ណារ៉ា បន្ថែមយ៉ាងនេះ។

**លក្ខខណ្ឌប្រលង**

**បេក្ខជន បេក្ខនារី ត្រូវតែមានថ្ងៃខែឆ្នាំកំណើតក្នុងចន្លោះរវាងឆ្នាំ១៩៦៨ ដល់ឆ្នាំ១៩៨៩។**

**បេក្ខភាពទាំងឡាយ មិនត្រូវធ្លាប់មានប្រវត្តិប្រព្រឹត្តបទល្មើស មិនធ្លាប់ជាប់ពន្ធនាគារ ឬក៏ធ្លាប់ទទួលទោសកម្រិតធ្ងន់ផងដែរ។ បេក្ខភាពទាំងអស់ក៏មិនត្រូវបានជាប់ឈ្មោះក្នុងបញ្ជីនិរទេស ឬមួយត្រូវបណ្តេញចេញពីសាធារណរដ្ឋកូរ៉េ និងមិនស្ថិតក្នុងស្ថានភាពនៃការហាមឃាត់មិនឱ្យធ្វើការចាកចេញពីព្រះរាជាណាចក្រកម្ពុជាជាដើម។**

កំពុងអង្គុយក្នុងថ្នាក់រៀននៃមជ្ឈមណ្ឌលហ្វឹកហ្វឺនភាសាកូរ៉េ អ៊ី ភី អេស កញ្ញា ទូច ស្រីម៉ៅ ដែលមានអាយុ ២៨ឆ្នាំ និយាយថា នាងមានការចាប់អារម្មណ៍លើការសិក្សាភាសាកូរ៉េនេះ។នាងបន្ថែមថា នៅពេលដែលនាងចេះភាសាកូរ៉េ នាងអាចធ្វើការជាមួយជនជាតិកូរ៉េបានយ៉ាងស្រួល។ ហើយកត្តាដែលធ្វើឱ្យនាងមកសិក្សាភាសាកូរ៉េ ដោយសារតែជីវភាពរបស់នាងសព្វថ្ងៃ មានការខ្វះខាត ទើបបានជានាងសម្រេចចិត្តមកសិក្សា ដើម្បីអាចទៅរកការងារធ្វើនៅប្រទេសកូរ៉េបាន។ នាងបន្តបញ្ជាក់ថា ប្រសិនបើនាងមានលទ្ធភាពច្រើន នាងនឹងមិនទៅធ្វើការនៅទីនោះទេ។

នៅជិតៗនោះដែរ លោក ចាយ គឹមអេង អាយុ ៣៧ឆ្នាំ ក៏ងាកមកចាប់អារម្មណ៍ផងដែរថា: "សព្វថ្ងៃនៅស្រុកខ្មែរយើង ឃើញមានអ្នកវិនិយោគទុនជនជាតិកូរ៉េជាច្រើន ដែលនេះគឺតម្រូវឱ្យកូនខ្មែរចេះកូរ៉េ ដើម្បីងាយស្រួលស្វែងរកការងារធ្វើ។" លោក ចាយ គឹមអេង បន្តថា ចំពោះភាសាកូរ៉េ ការរៀនមានការលំបាកខ្លះៗដែរ គឺដូចជា ការបញ្ចេញសំឡេង និងពាក្យមួយៗនៅក្នុងភាសាកូរ៉េនេះដែលគេអាចបកបានន័យជាច្រើន បើធៀបទៅភាសាខ្មែរ។ លោកបានបន្ថែមឱ្យដឹងអំពីមូលហេតុចម្បងៗរបស់លោក ដែលមករៀនភាសាកូរ៉េនេះថា ទីមួយ គឺលោករៀនដើម្បីស្វែងរកការងារធ្វើនៅប្រទេសកូរ៉េ និងទី២ ក្រោយបញ្ចប់ការងារនៅប្រទេសកូរ៉េ លោកនឹងរកការងារដែលប្រើភាសាកូរ៉េនៅស្រុកខ្មែរវិញ។

ផ្ទុយពីលោក ចាយ គឹមអេង លោកគ្រូទី ណារ៉ា បានឱ្យដឹងថា ពាក់ព័ន្ធទៅនឹងការសិក្សាភាសាកូរ៉េនេះ វាមិនមានអ្វីដែលពិបាកទេ។ នេះ គឺអាស្រ័យទៅលើការខិតខំប្រឹងប្រែង របស់សិក្ខាកាមម្នាក់ៗប៉ុណ្ណោះ។ ជាក់ស្តែង មជ្ឈមណ្ឌលហ្វឹកហ្វឺនភាសាកូរ៉េ អ៊ី ភី អេស ផ្តល់ឱកាសជាច្រើនដល់សិស្ស-និស្សិត ទាំងក្នុងការសិក្សាផង និងការរកប្រាក់ចំណូលថែមទៀតផង។ ដើម្បីទទួលបានជោគជ័យទៅលើការងារនៅប្រទេសកូរ៉េ គោលដៅសំខាន់គឺបញ្ហាភាសា ហើយនិងត្រូវមានកាយសម្បទារឹងមាំពោលគឺយើងត្រូវហាត់កីឡាដើម្បីឱ្យសុខភាពរបស់យើងបានរឹងមាំល្អផង។ លោកឆ្លៀតបន្ថែមបន្តិចទៀតថា ជាការពិតទៅ នៅប្រទេសកូរ៉េ គេមានពាក្យស្លោកមួយពោលថា: "ការងារគឺជាកីឡា"។

រីឯអ្នកនាង គឹម ហួរ អាយុ ៣៤ឆ្នាំ កំពុងសិក្សាភាសាកូរ៉េដែរនោះបានឱ្យយើងដឹងថា: "ភាសាកូរ៉េមានអត្ថប្រយោជន៍ច្រើន ដែលវាអាចផ្តល់ឱ្យយើងអាចរកការងារធ្វើនៅប្រទេសកូរ៉េផង និងក៏អាចទំនាក់ទំនងដោយប្រើភាសានេះជាមួយជនជាតិកូរ៉េផ្ទាល់សម្រាប់ការងារក្នុងស្រុកខ្មែរយើងផងដែរ។

...



នៅក្នុងថ្នាក់រៀនពួកគេត្រៀមខ្លួន និងសាកល្បងស្វែងរកអនាគតថ្មី

Photo: L. Samphors

... ទាក់ទងទៅនឹងការកើនឡើងនៃសាលាឯកជន ក៏ដូចជាការសិក្សាភាសាកូរ៉េនេះដែរ លោក គឹម វ៉ារ៉ា ក៏មានប្រសាសន៍ឱ្យដឹងដែរថា ការកើនឡើងនៃការសិក្សាភាសាកូរ៉េនេះ មានលក្ខណៈល្អប្រសើរ សម្រាប់ប្រជាពលរដ្ឋ ក៏ដូចជា សិស្ស-និស្សិតខ្មែរ។ លោកបន្ថែមថា ភាសាកូរ៉េគឺជាផ្នែកមួយដ៏មានសារៈសំខាន់ សម្រាប់ឱ្យពួកគេអាចឈោងចាប់យកការងារមួយ ដែលពួកគេត្រូវការ ជាពិសេសសម្រាប់ជាការបំពេញនូវកង្វះខាតមួយ ពោលគឺសព្វថ្ងៃនេះ ចំនួនប្រជាពលរដ្ឋដែលគ្មានការងារធ្វើ មានចំនួនយ៉ាងច្រើន។

តាមកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលកូរ៉េ និងរដ្ឋាភិបាលកម្ពុជា លើការបញ្ជូនពលករ-ការិនីខ្មែរ ទៅធ្វើការងារនៅសាធារណៈរដ្ឋកូរ៉េ ខាងភាគីកូរ៉េ ក៏បានផ្តល់នូវការអនុគ្រោះជាច្រើនក្នុងកិច្ចការនេះ។ បើយោងតាមគម្រោងនោះ គឺគេទទួលយកពលករ ពលការិនីខ្មែរទៅធ្វើការ រហូតដល់រាប់ពាន់នាក់ ក្នុងមួយឆ្នាំៗ នៅប្រទេសកូរ៉េ។ ជាមួយនេះដែរ កិច្ចការនេះក៏កំពុងធ្វើការជ្រើសរើសតាមរយៈការធ្វើតេស្តជាភាសាកូរ៉េដោយរួមសហការជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៃព្រះរាជាណាចក្រកម្ពុជាផងដែរ។ ជាក់ស្តែង កិច្ចការនេះទើបតែបានបញ្ចប់ការធ្វើតេស្តភាសាកូរ៉េ លើកទី១ កាលពីថ្ងៃ ទី០២ ខែមិថុនា ឆ្នាំ២០០៧ កន្លងមកនេះ។ ជាមួយនេះផងដែរ នៅថ្ងៃទី១៦ ខែកញ្ញា ខាងមុខនេះ នឹងមានរៀបចំការប្រឡងភាសាកូរ៉េជាលើកទី២ ទៀតផង។



Photo: L. Samphors

ក្រៅពីចំណេះភាសា ពលករត្រូវការរឹងមាំតាមរយៈការហាត់ប្រាណ

បើនិយាយអំពីទំនាក់ទំនងការទូតរវាងប្រទេសកម្ពុជា និងប្រទេសកូរ៉េខាងត្បូង គឺទើបតែមានអាយុកាល ជាង១០ឆ្នាំ ប៉ុណ្ណោះ ប៉ុន្តែចំនួនភ្ញៀវទេសចរណ៍ និងអ្នកវិនិយោគទុនរបស់ប្រទេសនេះ បានមកលេង និងមកដាក់ទុនរកស៊ីនៅក្នុងប្រទេសកម្ពុជា មានចំណាត់ថ្នាក់លេចធ្លោជាងប្រទេសដទៃៗទៀត។ កន្លងមកមានអ្នកជំនាញសេដ្ឋកិច្ចខ្លះនិយាយថា កូរ៉េគឺជាប្រទេសដៃគូអភិវឌ្ឍន៍មួយ ដែលប្រទេសកម្ពុជា មិនអាចខ្វះបាន។ ហើយនេះជាប្រទេសដែលមាននូវទីផ្សារការងារយ៉ាងធំ ដែលនឹងជួយស្រូបយកកម្លាំងពលកម្មពីប្រទេសកម្ពុជាក្នុងមួយឆ្នាំៗ អាចដល់រាប់ពាន់ រាប់ម៉ឺននាក់។

### ភាពជាក់ស្តែង

**កាលពីថ្ងៃទី៩ មករា ឆ្នាំ២០០៧ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៃព្រះរាជាណាចក្រកម្ពុជាបានចេញសេចក្តីជូនដំណឹងលេខ : ០៣៣ ០៧ ក.ក.ប.វ..., សជណ ស្តីពីការចុះហត្ថលេខាលើសិទ្ធិទទួលបានការអនុញ្ញាតក្នុងការបញ្ជូនពលករទៅធ្វើការស្របច្បាប់តែមួយគត់នៅសាធារណៈរដ្ឋកូរ៉េ។ សម្តេចនាយករដ្ឋមន្ត្រីក៏បានចុះហត្ថលេខាជាមួយប្រធានាធិបតីនៃសាធារណៈរដ្ឋកូរ៉េផងដែរ។**

## សេចក្តីណែនាំរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ



Photo: L. Samphors

មនុស្សម្នាកំពុងពពាក់ពពូនស្វែងរកព័ត៌មាននៅសាលាបណ្តុះបណ្តាលភាសាកូរ៉េមួយ

ការប្រឡងជាប់តេស្តភាសាកូរ៉េ គ្រាន់តែផ្តល់នូវលក្ខណៈសម្បត្តិដល់ការដាក់ពាក្យនៅក្នុងបញ្ជីអ្នកស្វែងរកការងារធ្វើប៉ុណ្ណោះ ហេតុនេះមិនធានាថានឹងទទួលបានការងារធ្វើនៅសាធារណរដ្ឋកូរ៉េទាំងស្រុងនោះឡើយ។

បេក្ខជនដែលមានបញ្ហាសុខភាព ឬអ្នកដែលធ្លាប់មានប្រវត្តិស្នាក់នៅខុសច្បាប់នៅក្នុងសាធារណរដ្ឋកូរ៉េនឹងមិនត្រូវអនុញ្ញាតឱ្យទៅធ្វើការងារនៅទីនោះឡើយ ទោះបីជាគាត់បានប្រឡងជាប់តេស្តភាសាកូរ៉េក៏ដោយ។

នៅក្រោមប្រព័ន្ធអនុញ្ញាតមុខរបរ គឺមានតែក្រុមប្រឹក្សាភិបាលបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេសតែមួយប៉ុណ្ណោះ ដែលមានសិទ្ធិស្របច្បាប់ក្នុងការបញ្ជូនពលករកម្ពុជាទៅធ្វើការនៅសាធារណរដ្ឋកូរ៉េ។ ក្រៅពីនេះ គឺគ្មានជនណាម្នាក់ ឬក្រុមហ៊ុនណាមួយអាចធានាស្វែងរកការងារជូនដល់ពលករកម្ពុជាស្របច្បាប់ទៅសាធារណរដ្ឋកូរ៉េ ដោយមិនបានឆ្លងកាត់ការប្រលងតេស្តភាសាកូរ៉េ និងការបញ្ចូលឈ្មោះក្នុងបញ្ជីអ្នកស្វែងរកការងារធ្វើដើម្បីឱ្យនិយោជក ឬក្រុមហ៊ុនកូរ៉េជ្រើសរើសជាចុងក្រោយនោះឡើយ។

អាស្រ័យដូចបានពោលមកខាងលើនេះ សូមបងប្អូនពលករដែលមានបំណងទៅធ្វើការនៅសាធារណរដ្ឋកូរ៉េ មិនត្រូវជឿតាមពាក្យធានាអះអាងរបស់ជនណាម្នាក់ ក្រុមហ៊ុន ឬសាលាណាមួយឱ្យសោះ ពីព្រោះថាមានតែអ្នកដែលបានប្រឡងជាប់តេស្តភាសាកូរ៉េ មិនមានបញ្ហាសុខភាព ព្រមទាំងបានដាក់ពាក្យសុំរកការងារធ្វើនៅក្រុមប្រឹក្សាភិបាលបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេសតែប៉ុណ្ណោះ ដែលត្រូវបានគេបញ្ជូនឈ្មោះចូលទៅក្នុងប្រព័ន្ធទិន្នន័យសម្រាប់អ្នកស្វែងរកការងារធ្វើរបស់អង្គភាពដែលមានព័ត៌មានទាំងអស់ ដែលប្រព័ន្ធនេះត្រូវបញ្ជូនមកដោយសារអេឡិចត្រូនិកដែលរៀបចំ និងដំឡើងដោយភាគីកូរ៉េ។

ហេតុដូចនេះអ្នកប្រព្រឹត្តអំពើឆបោក នឹងត្រូវទទួលទោសចំពោះមុខច្បាប់។

សម្រាប់ព័ត៌មានបន្ថែម សូមបងប្អូនប្រជាពលរដ្ឋអញ្ជើញទៅធ្វើការទំនាក់ទំនងជាមួយក្រុមប្រឹក្សាបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេសដែលមានទីតាំងស្ថិតក្នុងវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា នៅភូមិស្រែរាជ្យ សង្កាត់សំរោងក្រោម ខណ្ឌដង្កោ រាជធានីភ្នំពេញ ឬបងប្អូនអាចទំនាក់ទំនងមកកាន់ទូរស័ព្ទលេខ : ០២៣ ៣៥៥ ២១៤ / ០១១ ៣៨៣ ៧៣៥ ឬ ០១៦ ៣៧២ ៩៦៦ នៅរៀងរាល់ម៉ោង និងថ្ងៃធ្វើការ។

យោងតាមលិខិតអង្គភាពអភិវឌ្ឍន៍ធនធានមនុស្សនៃប្រទេសកូរ៉េចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០០៧ បេក្ខជន-នារី ដែលបានប្រឡងជាប់តេស្តភាសាកូរ៉េលើកទី១ ហើយបានទទួលពិន្ទុសរុបលើស ១២០ពិន្ទុ មានចំនួន ៣៩៦នាក់ និងពិន្ទុសរុប ចន្លោះ៦០-១១៩ពិន្ទុ មានចំនួន ១ ៥០៤នាក់ ក្នុងចំណោមបេក្ខជន-នារី ដែលមានសិទ្ធិប្រឡងទាំងអស់ចំនួន ២ ៩៧៧នាក់។

**អត្ថបទដោយឡុង សម្ផស្ស**





**អង្គការមនុស្សលោកថ្មីគឺជាអង្គការមនុស្សធម៌មួយដែលមានបេសកកម្មជួយអភិវឌ្ឍ និងធ្វើឱ្យរីកចម្រើនឡើងនូវការអប់រំសម្រាប់កុមារ យុវជន យុវនារី ស្ត្រី និងជនមានពិការភាព ដោយធ្វើការជាដៃគូជាមួយសហគមន៍តំបន់។ សព្វថ្ងៃអង្គការកំពុងដំណើរការនូវគម្រោងមួយជួយជនពិការនៅខេត្តកំពង់ឆ្នាំង។**

# អង្គការមនុស្សលោកថ្មីគាំពារដល់ជនពិការ



Photo: K. Kaghna

បុគ្គលិកមនុស្សលោកថ្មីទឹកឱ្យក្មេងពិការខួរក្បាល

ក្នុងដំណើរផ្អៀងផ្អង យុវជនម្នាក់បន្លឺសម្លេងទាំងលំបាកលំបិនថា: "ខ្ញុំឈ្មោះឌី រៀនថ្នាក់ទី៤ នៅឯសាលាអណ្តូងរវៀង។" ឌីមានមាត់វៀចមួយចំហៀង និងមានកាយសម្បទាដូចមនុស្សធម្មតាដែរ តែខួរក្បាលរបស់គាត់មិនអាចបញ្ជាបានភ្លាមៗទេ។ ប្រសិនបើយើងសួរគាត់ គាត់ត្រូវចំណាយពេលមួយស្របក់ ទើបអាចនិយាយមកវិញបាន។ ជារៀងរាល់ថ្ងៃ ឌី និងមិត្តភក្តិដទៃៗទៀត មកមណ្ឌលមួយដែលហៅថាមណ្ឌលពិការ ស្ថិតក្នុងគម្រោងមួយ របស់អង្គការមនុស្សលោកថ្មី ដែលមានមណ្ឌលពីរ គឺមួយនៅឃុំអញ្ចាញរូង និងមួយទៀតនៅឃុំពពេល ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង។ នៅក្នុងមណ្ឌល មានកុមារពិការ ចំនួន១៦នាក់ ដែលកំពុងកើតជំងឺ ដូចជាជំងឺរលាកខួរក្បាល ជំងឺខ្សោយសាច់ដុំ ជំងឺសាច់ដុំមាត់ ពិការភាពអវៈយវៈ និងមានជំងឺផ្សេងៗទៀត។

បងស្រីគ្រីស្ទីណា ដែលជាអ្នកស្ម័គ្រចិត្តមកពីប្រទេសអ៊ីតាលី និងក៏ជាទីប្រឹក្សា មណ្ឌលពិការ បានឱ្យដឹងថា កុមារក្នុងមណ្ឌល ដូចជា ឌី និងមិត្តម្នាក់ទៀតដែលអង្គុយក្បែរគេនេះ គឺមានជំងឺតាំងពីកំណើតមក។ ហើយអាការៈនេះមានសភាពធ្ងន់ធ្ងរ ដោយគេមិនអាចគ្រប់គ្រងចលនាខ្លួនឯងបានទេ ក្នុងពេលនៅជាមួយគ្នា ទាំងការនិយាយ និងការសរសេរអក្សរ។ បងស្រីបន្តថា គឺដូចជាមិត្តរបស់ឌីម្នាក់នេះ



Photo: H. Rann

មានជំងឺធ្ងន់ធ្ងរជាងឌីទៅទៀត ហើយអការៈនឹងបន្តទៅមុខដោយគាត់មិនអាចដើរបានខ្លួនឯងទេ គឺត្រូវអង្គុយលើរទេះរុញរហូត។

ក្រៅពីនេះអង្គការមនុស្សលោកថ្មីមានសេវាទៅតាមផ្ទះ ដែលមានអ្នកពិការ ១១នាក់ទៀត ដែលមិនអាចធ្វើដំណើរទៅកាន់មណ្ឌលបានដោយឪពុកម្តាយមានការរវល់ ឬផ្ទះនៅឆ្ងាយពីមណ្ឌលពេក។ តួយ៉ាងកុមារស៊ុន លី មានអាយុ ១៥ឆ្នាំ។ រាល់ថ្ងៃៗ លោកគ្រូលឹម ហេង បុគ្គលិកអង្គការមនុស្សលោកថ្មី តែងតែមកបង្រៀន និងធ្វើសរសៃឱ្យគេយ៉ាងតិច ២ម៉ោង។ លោកលឹម ហេង បានឱ្យដឹងអំពីអាការៈរបស់ស៊ុន លីថា ខួរក្បាលគាត់មានបញ្ហា ពេលដែលយើងហៅគាត់ គាត់ចេះតែទះដៃ ហើយពេលដែលឮសំឡេងឡាន ឬធុងបាស គាត់ក្រឡេកភ្លាមទៅរកសំឡេង ហើយក៏ទះដៃអរសប្បាយទៀតផង។ លោកគ្រូ បន្តថា ស៊ុន លី បានត្រឹមតែអង្គុយ និងរំកិលបាន។ កាលពីមុនគាត់មិនអាចអង្គុយលេងអ៊ីចឹងផង តែដោយសារយើងធ្វើចលនាឱ្យ ទើបគាត់អាចអង្គុយលើតុយ៉ាងនេះបាន។

អ្នកស្រីឡាប ស៊ី ដែលជាស្ត្រីមេម៉ាយមានកូន ៧នាក់ និងជាម្តាយរបស់កុមារីពិការជើងម្នាក់ បានប្រាប់ថា កាលពីមុន កូនរបស់គាត់ដើរអត់រួចទេដោយសារខ្នងជើងបត់ទៅខាងក្រោយ។ ប៉ុន្តែឥឡូវនេះកូនស្រីរបស់គាត់អាចដើរបានធម្មតាវិញហើយ។ ស្ត្រីមេម៉ាយរូបនេះបន្តសំដីទាំងទឹកចិត្តរំភើបថា : "ខ្ញុំសប្បាយចិត្តណាស់ដោយអង្គការមនុស្សលោកថ្មី បានជួយ និងយកកូនខ្ញុំមកទីនេះ ដើម្បីឱ្យរៀននៅសាលារដ្ឋផង និងរៀននៅមណ្ឌលទៀតផង ហើយអង្គការក៏បានជួយចិញ្ចឹមខ្ញុំផងដែរ។" ក្តីសង្ឃឹមរបស់ស្ត្រីមេម៉ាយរូបនេះ គឺចង់ឱ្យកូនគាត់រៀនបានពូកែ និងមានការងារធ្វើដើម្បីអាចជួយរូបគាត់វិញបាននៅពេលអនាគត។

បងស្រីគ្រីស្ទីណាបានលើកឡើងអំពីកម្មវិធីនេះថា អ្វីដែលសំខាន់គឺជនពិការទាំងនេះមានអារម្មណ៍ថា ពួកគេជាមនុស្សគ្មានតម្លៃ គ្មានអ្នករាប់រក និងមិនមានអ្នកណាស្រឡាញ់ពួកគេ។ ដូច្នេះ ជាជំហានដំបូង យើងត្រូវឱ្យពួកគេដឹងថាមានមនុស្សជាច្រើនដែលស្រលាញ់ពួកគេ និងឱ្យពួកគេមាននូវសេចក្តីសង្ឃឹម ហើយចំនុចដែលយើងចាប់ផ្តើម គឺពីឪពុកម្តាយរបស់ពួកគេ។

**កែវ កញ្ញា**

### អំពីគម្រោងនេះ

**គម្រោងមណ្ឌលជនពិការនេះបានចាប់ផ្តើមដំណើរការឡើងនៅឆ្នាំ២០០៦ ដោយមានការឧបត្ថម្ភពីអង្គការមនុស្សលោកថ្មី។ ហើយកម្មវិធីរបស់អង្គការក៏មានការបំពាក់បំប៉នលោកគ្រូ អ្នកគ្រូចំនួន ៧នាក់ ឱ្យចុះទៅធ្វើកម្មសិក្សានៅអង្គការនានា និងសាលា ដូចជានៅសាលាឡាវ៉ាឡា ពេទ្យរុស្ស៊ី (ផ្នែកវិបត្តិផ្លូវចិត្ត) សាលាទន្សាយ និងមានការបណ្តុះបណ្តាលពីអង្គការផ្សេងៗទៀត រួមទាំងមានការជួយបង្រៀនឱ្យធ្វើចលនាសរសៃដល់ក្មេងៗ ពីសំណាក់វេជ្ជបណ្ឌិត អេលីណាមកពីប្រទេសអ៊ីតាលីផងដែរ។ មណ្ឌលជនពិការនេះអាចទទួលមនុស្សពិការអាយុពី១ឆ្នាំ ដល់៣៥ឆ្នាំ។ ហើយក្នុងមួយឆ្នាំៗ មណ្ឌលពិការនេះត្រូវចំណាយអស់ថវិកាអស់ចំនួន ១៧០០០ដុល្លារ។**

**តាមប្រពៃណីខ្មែរ នៅពេលដែលក្រុមគ្រួសារណាទើបសាងសង់គេហដ្ឋានថ្មីរួចរាល់ហើយ ពួកគេតែងតែរៀបចំពិធីឡើងគេហដ្ឋានថ្មីនោះដើម្បីបង្ហាញឱ្យញាតិមិត្តជិតឆ្ងាយដឹងថាគេមានផ្ទះថ្មី។ ប្រពៃណីខ្មែរក្នុងពិធីឡើងគេហដ្ឋានមានតាំងពីយូរយារណាស់មកហើយ។ តើពិធីនេះរៀបចំដោយរបៀបណា និងដើម្បីអ្វីដែរ ?**

# ទំនៀមទម្លាប់នៃពិធីឡើងផ្ទះខ្មែរ


ផ្ទះសង់រួចហើយត្រូវរៀបចំពិធីចូលទៅនៅដើម្បីមានសិរីសួស្តី

Photo: S. Chum

ជាប្រពៃណីល្អរបស់ខ្មែរ កាលណាគេហដ្ឋានថ្មីត្រូវបានគេសាងសង់រួចហើយ គេក៏រកវេលាល្អដើម្បីឡើងគេហដ្ឋានថ្មីនោះ ដោយមានរៀបចំនូវប្រដាប់គ្រឿងដើម្បីធ្វើទៅតាមទំនៀមទម្លាប់។

ប្រដាប់ទាំងនោះ មានបង្អែម ចម្អាប ស្រូវមួយការ៉ុង បន្លែ និងផ្លែឈើ។ ប្រដាប់ធ្វើស្រែចំការ គឺមានកាំបិត កណ្ដៀវ កញ្ជើ និងល្អី។ ប្រដាប់ស្លៀកពាក់មានដូចហិបដាក់សំពត់អាវ មួក ឆ័ត្រនិងគ្រឿងមាសប្រាក់។ គ្រឿងស្អាងខ្លួនប្រេងម្សៅ កញ្ចក់ ក្រាស់ កន្ត្រៃ និងកាំបិតកោរ។ គ្រឿងដំណេក ដូចមានកន្ទេល ពូក ខ្នើយ និងមុង។ បារីស្លា ប្រអប់ស្លា បាយព្រលឹង និងក្អមទឹកសិរីទ្ធ។ បើគ្មាន គេក៏ឱ្យយកផ្តិលសិរីទ្ធ ឬក៏ផ្តិលលុងហិន ភ្លុក សង្ខ ផ្លែដូងទុំ ត្រឡាច ឆ្នាញីសម្បុរបី១ គ្រឿងសារពើយុទ្ធ "គ្រឿងចម្បាំង"-ល-។ របស់របរអំបាលម៉ាននេះឱ្យរៀបចំនៅមុខទីផ្ទះថ្មី។ អាចារ្យអ្នកដឹកនាំឡើងផ្ទះ ត្រូវរើសរកស្រី៧មក សន្មតដាក់ឈ្មោះជាថ្មីថា នាងស្រី "ដើម្បីឱ្យកើតនូវសេចក្តីត្រេកអរ" នាងសួស្តី "ដើម្បីឱ្យកើតសេចក្តីសួស្តី" នាងកែវ "ដើម្បីឱ្យកើតនូវមាសប្រាក់កែវកង" នាងគង់ "ដើម្បីឱ្យគង់ជីវិត ឬក៏គង់ទ្រព្យសម្បត្តិ" និងនាងជ័យ "ដើម្បីឱ្យកើតនូវជ័យជោគ និងសុភមង្គល"។

ហើយរើសរបស់សំខាន់ៗ ឱ្យស្រីៗទាំងនេះកាន់ហែឡើងផ្ទះ គឺនាងស្រីកាន់ក្អម ឬផ្តិលទឹក។ នាងរ័តន៍កាន់គ្រឿងស្លា។ នាងសួស្តីកាន់សំពត់អាវ។ នាងគង់ឱ្យកាន់ពូក និងកន្ទេល។ ហើយនាងកែវក៏ឱ្យកាន់ មាស និងប្រាក់កែវកង។ ចំណែកនាងជ័យវិញ ឱ្យកាន់គ្រឿងភ្លុក និងកុយជាដើម។

ពួកអ្នកក្រៅពីនេះ គឺឱ្យកាន់ទ្រព្យរបស់ផ្សេងៗ ដូចពោលខាងលើ ដើរដង្ហែអ្នកម្ចាស់ផ្ទះ ជុំវិញផ្ទះបីជុំ ហើយអ្នកម្ចាស់ផ្ទះ មានគេបាំងឆ័ត្រឱ្យផង។ វេលានោះមនុស្សចាស់ខ្លះ ប្រមាណ២-៣នាក់ ត្រូវឡើងទៅលើផ្ទះមុន កាលណាដង្ហែបាន៣ជុំហើយ។ អ្នកនៅលើផ្ទះធ្វើជាស្រែកសួរមកថា : "អ្នកណាមកពីណា គ្នាច្រើនម្ល៉េះ។" អ្នកទាំងនោះឆ្លើយថា: "យើងមកពីឆ្ងាយនាំគ្រឿងឧបភោគ បរិភោគ មានមាសពេជ្រកែវកងជាដើម ច្រើនណាស់។ មករកទីលំនៅនៅដោយឮថា នៅទីនេះមានផ្ទះមួយទំនេរ។ យើងចង់មកនៅផ្ទះនេះ តើវាល្អមយើងនៅបានសេចក្តីសុខសប្បាយឬទេ?។" អ្នកនៅខាងលើឆ្លើយតបថា: "អើ! បើអ៊ីចឹង អញ្ជើញឡើងមកនៅចុះ ផ្ទះនេះបើសិនអ្នកណាបាននៅហើយ អ្នកនោះនឹងបានសេចក្តីសុខសប្បាយចម្រើនទ្រព្យសម្បត្តិបរិបូណ៌គ្រប់ប្រការហោង"។ វេលានោះ អ្នកហែក៏នាំគ្នាឡើងទៅលើផ្ទះ។ កាលណាឡើងលើផ្ទះគ្រប់គ្នាហើយ ត្រូវរៀបចំសែនរំឭកដល់ជីដូនជីតាដែលបានចែកឋាន និងព្រះភូមិដែលជាម្ចាស់ទឹកដី ដើម្បីឱ្យសព្វសាធុការពរដល់កូនចៅ ដែលមកនៅក្នុងទីនេះឱ្យបានសេចក្តីសុខសប្បាយ-ល-។

**សម្រង់ពីសៀវភៅ ទំនៀមទម្លាប់ និងពិធីបុណ្យផ្សេងៗ**

**ទំនៀម**

**រៀបចំសែនរំឭកដល់ជីដូនជីតាដែលចាកឋានទៅហើយ និងព្រះភូមិជាម្ចាស់ទឹកម្ចាស់ដី។ សូមអញ្ជើញសេពសោយគ្រឿងបូជា។ ចូរឱ្យសព្វសាធុការពរដល់កូនចៅដែលមកនៅក្នុងទីនេះឱ្យបានសេចក្តីសុខសប្បាយ។ល។ ស្រេចហើយអាចារ្យយកអំបោះសជ្រលក់ក្នុងប្រេងម្សៅក្រអូបយកចងដៃឱ្យប្តីប្រពន្ធម្ចាស់ផ្ទះ និងឱ្យពរជ័យ ឱ្យបានសេចក្តីសុខសប្បាយ និងសេចក្តីចម្រើនទ្រព្យគ្រប់ប្រការ។**





# អ័រគីដេជាផ្កាប្រកបដោយសោភ័ណភាព

**ដើម្បីលំអគេហដ្ឋានឱ្យមានភាពស្អាតបាត ប្រជាពលរដ្ឋមួយចំនួននិយមដាំផ្កា ពីព្រោះវាគឺជារុក្ខជាតិមួយបែបស្រស់បំព្រងទាក់ទាញភ្នែក និងជួយធ្វើឱ្យរសាយទុក្ខកង្វល់ និងភាពនឿយហត់បានខ្លះៗដែរ។ ផ្កាមានច្រើនប្រភេទណាស់ ប៉ុន្តែអ័រគីដេគឺជាជម្រើសមួយព្រោះវាស្អាត និងមានប្រភេទដែលមានពណ៌ច្រើន។**


គេដាំផ្កាអ័រគីដេដាក់ក្នុងផើងស្រកីដូង មានរន្ធខ្យល់ និងចងយួរឱ្យផុតពីដី

Photo: P. Samphy

កញ្ញាអ៊ិន សុខភាព អាយុ ២៦ឆ្នាំ ជាម្ចាស់កសិដ្ឋានផ្កាអ័រគីដេ នៅទល់មុខភូមិគ្រឹះឯកឧត្តមជា សុផារ៉ា បានមានប្រសាសន៍ថា :

ផ្កាអ័រគីដេ យើងនាំចូលមកពីស្រុកថៃ។ នៅទីនោះ គេនិយមយកផ្កានេះទៅថ្វាយព្រះ។ ចំណែកនៅទីនេះ អតិថិជនយើងនិយមទិញយកទៅលំអគេហដ្ឋាន តាមពិធីបុណ្យ ឬក៏ពិធីជប់លៀងផ្សេងៗ។ អតិថិជនខ្លះៗទៀត ចូលចិត្តទិញអ័រគីដេ យកទៅលំអកន្លែងរកស៊ី ឬកន្លែងមុខរបររបស់ខ្លួនដូចជាភោជនីយដ្ឋាន ឬសណ្ឋាគារជាដើម ដើម្បីទាក់ទាញភ្ញៀវរបស់ខ្លួនឱ្យបានច្រើន។

អ័រគីដេមានច្រើនប្រភេទណាស់។ តែមានប្រភេទតិចតួចប៉ុណ្ណោះដែលមានក្លិន។ ក្រៅពីនេះ ប្រភេទផ្សេងៗទៀតគឺមានពណ៌ចម្រុះគ្នាយ៉ាងស្អាត ដូចជា ពូជស្រីរាំ និងប៉ាឡេណូស៊ីសជាដើម តែយើងមិនអាចរាប់ឈ្មោះទាំងអស់បានទេ។

អ័រគីដេគឺជាប្រភេទផ្កា ដូចជា រុក្ខជាតិបញ្ញើក្អែកដែរ វារស់លើខ្លួនប្រាណដទៃ។ ដូច្នេះយើងពុំអាចដាំនៅលើដីបានឡើយ។ គេនិយមដាំវាដោយប្រើផើងធ្យូង ឬស្រកីដូងដែលមានប្រហោងព្យួរឡើងលើដើម្បីឱ្យវាមានខ្យល់ដកដង្ហើម និងកុំឱ្យរលួយដើម។ ប៉ុន្តែនៅស្រុកខ្មែរការដាំដោយប្រើស្រកីដូង មានភាពប្រសើរជាង ពីព្រោះអាកាសធាតុស្រុកខ្មែរក្តៅ។ ការដាំដាក់ផើងធ្យូង វាឆាប់ស្ងួត ធ្វើឱ្យអន់ដើម។ ចំណែកការប្រើស្រកីដូងវិញ ធ្វើឱ្យជក់ទឹកបានយូរ។

ការដាំប្រភេទផ្កានេះ យើងត្រូវយកចិត្តទុកដាក់ស្រោចទឹក។ ក្នុងមួយថ្ងៃ យើងស្រោចទឹក ២ដង។ បើធាតុអាកាសក្តៅ យើងអាចស្រោចទឹកបីដង។ ប៉ុន្តែបើមានភ្លៀងហើយ យើងមិនបាច់ស្រោចក៏បាន។ យើងត្រូវរក្សាសំណើមក្នុងស្រកីដូងឱ្យជាប់ជានិច្ច។ កាលណាស្ងួត ធ្វើឱ្យស្រមោច សត្វល្អិតចូល ឬធ្វើឱ្យអន់ដើម។

តាមធម្មតា រុក្ខជាតិផ្កាអ័រគីដេនេះ បើដាំតាំងពីកូនតូចរហូតដល់វាចេញផ្កា គឺមានរយៈពេលជាងមួយឆ្នាំ។ ហើយវាចេញផ្កាម្តងៗ គឺពីមួយខែទៅមួយខែកន្លះ តែប្រភេទខ្លះ ចេញបានតែមួយសប្តាហ៍ប៉ុណ្ណោះ។ តែយើងអាចដាំដុះល្អ ដោយប្រើជីបំប៉នដើម ជីការពាររលួយ ឬជីដាក់ឱ្យឆាប់ចេញផ្កា។ ហើយយើងក៏អាចបាញ់ថ្នាំដើម្បីឱ្យផ្ការីកបានយូររហូតដល់ជាងមួយខែដែរ។ ហើយជី និងថ្នាំទាំងអស់នេះមានប្រភេទពិសេស ដែលយើងត្រូវតែនាំចូលពីស្រុកថៃ។ រុក្ខជាតិអ័រគីដេនេះ វាមិនសូវមានសត្វល្អិត ឬក៏ដង្កូវអ្វី មកបំផ្លាញទេ។ ហើយនៅពេលយើងដាំ បានត្រឹមត្រូវនោះ វាបែកកូនដោយខ្លួនឯង។ យើងអាចដាំបន្តដោយពង្រីកផើងឱ្យធំជាងមុន។

**ផាត សំភី**

**សិក្សាកសិកម្ម**

**ប្រសិនបើប្រិយមិត្តមានបំណងចង់សិក្សាអំពីវិធីសាស្ត្រ ឬបច្ចេកទេសខាងកសិកម្មគ្រប់ប្រភេទ ដូចជាការចិញ្ចឹមសត្វ ឬដាំដំណាំផ្សេងៗ គឺមានបង្រៀននៅមជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា ហៅ សេដាក ឬបុគ្គលិកសេដាកអាចទៅបង្រៀនដល់ទីកន្លែងផ្ទាល់ដោយគិតក្នុងតម្លៃសមរម្យ។ ប្រិយមិត្តអាចទាក់ទងទូរស័ព្ទ : ០២៣ ៨៨០ ៩១៦។**

## សុខភាព

# រលាកស្រោមខួរ

**សុខភាពគឺជាបញ្ហាសំខាន់។ មិនថាជំងឺអ្វីនោះទេ តែកើតឡើងហើយ គឺតែងតែផ្តល់នូវផលលំបាក ឬប៉ះពាល់ដល់អាយុជីវិតជាក់ជាមិនខាន បើយើងមិនបានស្វែងយល់ និងយកចិត្តដាក់ក្នុងការព្យាបាលទេនោះ មានដូចជាជំងឺរលាកស្រោមខួរក្បាលជាដើម។**

លោក វិន សំណាង ជាវេជ្ជបណ្ឌិត នៅអង្គការក្តីសង្ឃឹមថ្មីនៃកុមារកម្ពុជា បានឱ្យដឹងថា រលាកស្រោមខួរក្បាលជាជំងឺដែលបង្កឡើងដោយមេរោគជាច្រើនក្រុម ធ្វើឱ្យរលាកដល់ផ្នែកមួយ ឬផ្នែកទាំងមូលរបស់ស្រោមខួរ។ មេរោគទាំងនោះមានពពួកបាក់តេរីផ្សេងៗ មេរោគរបេង ពពួកផ្សិត និងពពួកវីរុសផងដែរ-ល-។

កត្តាដែលធ្វើឱ្យមេរោគទាំងនោះឆ្លងរលាកស្រោមខួរក្បាលបាន គឺដោយសារ អ្នកជំងឺធ្លាប់កើតជំងឺរលាក នៅលើសរីរាង្គផ្សេងៗ ដូចជា រលាកផ្លូវដង្ហើម សួត ទងសួត បំពង់ក ច្រមុះ ត្រចៀក ឬសន្ទះត្រចៀក-ល- ហើយមិនបានព្យាបាលត្រឹមត្រូវ ដែលធ្វើឱ្យមេរោគឆ្លងទៅស្រោមខួរក្បាល។ សម្រាប់អ្នកផ្ទុកមេរោគអេដស៍ គឺងាយរលាកស្រោមខួរដោយពពួកមេរោគផ្សិត។ ឯបងប្អូនរងគ្រោះថ្នាក់ ឬបាក់បែកធ្លាយឆ្អឹងមកក្រៅ នឹងមិនបានលាងសំអាត ឬព្យាបាលត្រឹមត្រូវ ក៏អាចធ្វើឱ្យមេរោគឆ្លងទៅស្រោមខួរក្បាលបានដែរ។

ជំងឺរលាកស្រោមខួរ កើតលើមនុស្សគ្រប់វ័យទាំងអស់ ជាពិសេសចំពោះក្មេង ដែលមានរោគសញ្ញាសំខាន់ៗ ប្រែប្រួលមិនទៀងទាត់ ដូចជាកើនកម្តៅភ្លាមៗតែម្តង រហូតដល់៣៩ ទៅ៤០អង្សា។ ក្មេងឡេះឡះ ប្រកាច់ៗ ក្អួត និងមិនឃ្លានអាហារ។ ចំពោះក្មេងកាន់តែតូច បង្ហើយក្បាលប៉ោងធំ និងគិតតែពីយំមិនឈប់។ សម្រាប់ក្មេងធំ ឬមនុស្សចាស់មានរោគសញ្ញាច្រើនទៀតដូចជាក្តៅខ្លួន ក្អួត ទន់ដៃទន់ជើង ក្រហាយដៃជើង ឈឺក្បាលខ្លាំង រឹងក-ចង្កេះ ប្រកាច់ៗ ហើយអាចសន្លប់បាត់បង់ស្មារតីរហូតដល់បាត់បង់ជីវិត។ ទន្ទឹមនឹងរោគសញ្ញាទាំងនេះគ្រូពេទ្យអាចបូមទឹកខួរឆ្អឹងខ្នង យកទៅពិនិត្យដើម្បីវិនិច្ឆ័យរោគ និងព្យាបាលទៅតាមនោះ។

លោកវេជ្ជបណ្ឌិតវិន សំណាង ផ្តាំផ្ញើថា បើសិនបងប្អូនប្រជាពលរដ្ឋឃើញកូនតូចៗ ឬអ្នកជំងឺមានអាការៈមិនស្រួលដែលអាច ជារោគសញ្ញារលាកស្រោមខួរ សូមនាំអ្នកជំងឺមកកាន់មណ្ឌលសុខភាព ឬជួបនឹងវេជ្ជបណ្ឌិតជំនាញ ដើម្បីទទួលការព្យាបាលឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា។

ផាត សំភី


Photo: Phat Samphy

វេជ្ជបណ្ឌិតវិន សំណាង សម្របសម្រួលរវាងពេទ្យរដ្ឋ និងអង្គការ

**វ៉ាក់សាំងបង្ការ**

**សព្វថ្ងៃនេះ វ៉ាក់សាំងការពាររលាកស្រោមខួរក្បាលនៅវិទ្យាស្ថានប៉ាស្ទ័រកម្ពុជាមិនទាន់បានប្រើប្រាស់ឱ្យបានទូលំទូលាយនៅឡើយ ហើយវាមានសម្រាប់ការពារមេរោគតែមួយចំនួនប៉ុណ្ណោះ។**

# លោកម៉ម ប៊ុណ្ណារ៉ាយ : "មិនមាននរណាជួយខ្ញុំ ក្រៅពីព្រះជាម្ចាស់"



Photo: H. Soktheary

**អ្នកកវីនិពន្ធគឺជាមនុស្សដែលមានមនោសញ្ចេតនាច្រើន និងមានភាពស្ងប់ស្ងាត់។ លោកម៉ម ប៊ុណ្ណារ៉ាយ ជាគ្រីស្តបរិស័ទ ដែលអាចនិពន្ធបទចម្រៀង ទំនុកច្រៀង និងជាអ្នកលេងព្យាណូយ៉ាងចំណានផងដែរ។**

លោកម៉ម ប៊ុណ្ណារ៉ាយ ជាអ្នកនិពន្ធតាំងពីលោកនៅវ័យក្មេង បានមានប្រសាសន៍ឱ្យដឹងថា: "បានជាខ្ញុំចាប់យកអាជីពជាអ្នកនិពន្ធ ដោយសារតាំងពីខ្ញុំចាប់កំណើតមក ខ្ញុំបានឃើញគេលេងភ្លេង-តន្ត្រីបាត់ទៅហើយ ។ ហើយម្យ៉ាងទៀតគ្រួសាររបស់ខ្ញុំ ជាពិសេសគឺប្រុសៗ គឺចេះភ្លេងទាំងអស់ ។" លោកបន្តថា ឪពុកលោកជាអ្នកកូត-វីយ៉ូឡុង និងជាអ្នកចម្រៀង ។ មកដល់នៅសម័យលន់នុល លោកមានការចាប់អារម្មណ៍នឹងបទភ្លេង លោកក៏ចាប់ផ្តើមសរសេរតែម្តង ។ សម័យនោះបានជាគេកោតសរសើរលោក ព្រោះលោកបានសរសេរ និងនិពន្ធបានស្នាដៃច្រើនណាស់ ។ លុះដល់សម័យប៉ុលពត ក៏មានមេខ្មែរក្រហមម្នាក់ដឹងថា លោកជាអ្នកនិពន្ធ ។ គេចូលចិត្តលោក ។ ហេតុនេះហើយទើបបានជាលោកអាចរស់បន្តការនិពន្ធបាន ។ ពេលនោះលោកមានអាយុប្រមាណជា ៤០ឆ្នាំ ។ នៅក្នុងការនិពន្ធនេះ លោកបានឱ្យដឹងដែរថា លោកមិនបានប្រើរយៈពេលយូរទេ ដោយសារព្រះអង្គប្រទានពរដល់លោក ។ លោកគ្រាន់តែដាក់ក្រដាសមកគឺអាចច្រៀងតែម្តង ហើយវាក៏មិនមានពិបាកអ្វីឡើយសម្រាប់លោក ដោយលោកប្រើអារម្មណ៍ និងគំនិតក្នុងការនិពន្ធ ។ បទដែលលោកចាប់ផ្តើមនិពន្ធ នៅក្នុងព្រះវិហារដំបូង ជាបទ : "ធមិឱព្រះបិតា" ។ អ្វីដែលធ្វើឱ្យលោកចាប់អារម្មណ៍និពន្ធសម្រាប់ព្រះវិហារ ព្រោះដូនតារបស់លោក សុទ្ធសឹងជាគ្រីស្តបរិស័ទ ។ ហើយពេលដែលលោកល្បី ក៏នៅក្នុងនាមជាគ្រីស្តបរិស័ទ ។ ហើយលោក បានបន្តទៀតថា ជីតារបស់លោក និងរូបលោកផ្ទាល់បាននិពន្ធបទចម្រៀងឱ្យព្រះវិហារច្រើនណាស់ ។ ហើយចំពោះរូបលោក នៅក្នុងការនិពន្ធនេះ លោកបានគូសបញ្ជាក់ឱ្យដឹងថា គ្មាននរណាជាអ្នកជួយលោកទេគឺមានព្រះអង្គទេដែលចាំជួយជានិច្ច ។ ក្រៅពីបញ្ចេញនូវស្នាដៃនិពន្ធឱ្យព្រះវិហារ និងព្រះសហគមន៍ហើយនោះ លោកបានបន្សល់ទុក នូវបទចម្រៀងជាច្រើន សម្រាប់អ្នកចម្រៀងជំនាន់ដើមផងដែរ ដូចជាសម្រាប់អ្នកស្រីប៉ែន រ៉ន ហួយ មាស រស់ សេរីសុទ្ធា និង លោកស៊ីន ស៊ីសាមុត-ល-។ បទដែលធ្វើឱ្យគេទទួលស្គាល់អ្នកនិពន្ធរូបនេះនាសម័យលន់នល់ មានបទ "ភ្នែកអើយ" ដែលច្រៀងដោយអ្នកស្រីប៉ែន រ៉ន ។ លោកក៏និយាយទៀតថា បទចាស់ៗដែលលោកនិពន្ធគឺមានច្រើនណាស់ ប៉ុន្តែដោយភាពអកុសល ពេលពួកប៉ុលពតចូលមក ក៏ពួកវាបំផ្លាញអស់ច្រើន ។ លោកនៅរើសបានតែស្រោមថាសមួយគត់ គឺអាល់ប៊ុម "កំពង់ធំជំរុំចិត្ត" ដែលមានរូបថតលោកនៅពីក្រោយតែម្តង ហើយបទនេះផ្ទាល់គឺលោកជាអ្នកនិពន្ធ ។ បទកំពង់ធំជំរុំចិត្តគឺទទួលបានជោគជ័យរហូតមកដល់ពេលនេះតែម្តង ។

"ខ្ញុំមានបំណងចង់ផ្ទេរចំណេះដឹង ដែលខ្ញុំមានទាំងអស់ឱ្យកូនចៅ ឬអ្នកដទៃ ដែលពួកគេមាននិស្ស័យខាងការនិពន្ធ និងសរសេរនេះ ។" នេះគឺជាការតាំងចិត្ត និងចង់រក្សាទុកនូវស្នាដៃតែងនិពន្ធរបស់លោក ឱ្យដល់កូនចៅជំនាន់ក្រោយរបស់លោកម៉ម ប៊ុណ្ណារ៉ាយ ។

**រតនា និងធារី**

មណ្ឌលផ្សព្វផ្សាយព័ត៌មានកាតូលិក មានចេញលក់នូវស៊ីឌីចម្រៀងវ៉ុលទី៦ ថ្មី ដែលពិពណ៌នាអំពីព្រះនាងម៉ារីឡើងស្ថានបរមសុខ និងចម្រៀងកោតសរសើរព្រះនាង។ តម្លៃក្នុងមួយ ស៊ីឌីគឺ ៨ ០០០រៀលតែប៉ុណ្ណោះ។ ប្រសិនប្រិយមិត្តចាប់អារម្មណ៍ សូមទំនាក់ទំនងតាម អាសយដ្ឋានខាងក្រោម ឬទូរស័ព្ទ : ០១២ ២៤៤ ៧៧៨។

សូមអរគុណ !

## គម្រោងព្រះសហគមន៍

- ថ្ងៃទី១-៦ កញ្ញា : សិក្ខាសាលាការ៉ូល និងសេដ្ឋា លើប្រធានបទ "ការទំនាក់ទំនងបុរស និងស្ត្រី" នៅព្រះសហគមន៍កំពង់ធំ។
- ថ្ងៃទី៦-៨ កញ្ញា : ប្រជុំក្រុមកាយឫទ្ធិនៅក្រុងកែប ដែលមកពីព្រះសហគមន៍ជុំគីរី ចំការទៀង មានប្រមាណជាង ៤០០នាក់។
- ថ្ងៃទី១១-១២ កញ្ញា : មានសិក្ខាសាលាសម្រាប់ភូមិភាគភ្នំពេញ ដែលមាន ៤០ ព្រះសហគមន៍ចូលរួម ក្នុងគោលបំណងឱ្យគេស្គាល់ និងចេះបទចម្រៀងក្នុងអភិបូជា។
- ថ្ងៃទី១១-១២ កញ្ញា : ព្រះសហគមន៍សៀមរាប ស្វាគមន៍ភ្ញៀវជាយុវជនកូរ៉េ ៤២ នាក់ ដែលមកស្វែងយល់អំពីសកម្មភាពរបស់យុវជននៅព្រះសហគមន៍សៀមរាប។
- ថ្ងៃទី១៧ កញ្ញា : សម្ពោធសាលាមត្តេយ្យនៅព្រះសហគមន៍ស្នួង ភូមិភាគកំពង់ចាម។
- ថ្ងៃទី១៨-២១ កញ្ញា : សន្និបាតទូទាំងប្រទេសរបស់ក្រុមវិនសេន ឌឺ ប៉ូល មានចំនួន ៧០ នាក់ចូលរួម នៅព្រះសហគមន៍ក្រុងព្រះសីហនុ។
- ថ្ងៃទី២១ កញ្ញា : លោកឪពុកសុកឃី ទទួលខុសត្រូវព្រះសហគមន៍ស្នួងទៅវិស្សមកាលនៅកូរ៉េរយៈពេល ៤ខែ គឺរហូតដល់ថ្ងៃទី២១ មករា ឆ្នាំ២០០៨ ទើបត្រឡប់មកវិញ។
- ថ្ងៃទី២១ កញ្ញា : បុណ្យសន្តិតេរ៉េសានៃព្រះកុមារយេស៊ូ នៅព្រះសហគមន៍ចំណោម ភូមិភាគបាត់ដំបង។
- ថ្ងៃទី២៨-២៩ កញ្ញា : ពិធីបុណ្យកាន់បិណ្ឌ នៅព្រះសហគមន៍ចំណោម។
- ថ្ងៃទី៣០ កញ្ញា : មានសិក្ខាសាលាគ្រូអប់រំជំនឿ ចំនួន ២៥នាក់ នៅព្រះវិហារសន្តយ៉ូសែប-រាជធានីភ្នំពេញ។

## សេវាកម្មចំណាន !

ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក មានបម្រើសេវាកម្មបំប្លែងពីកាសែតវីដេអូ VHS ទៅ VCD និង DVD។ បំប្លែងពីកាសែតម៉ាញ៉េ ទៅជា CD និង MP3 និងមានទទួលថតចម្លង CD VCD និងDVD គ្រប់ប្រភេទផងដែរ។ គ្រប់សេវាកម្មទាំងនេះនឹងធ្វើក្នុងតម្លៃសមរម្យ។ សូមប្រិយមិត្តទំនាក់ទំនងតាមទូរស័ព្ទ : ០១២ ៣៧៧ ៤៦០។

**សូមអរគុណ !**

ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក : ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧មករា រាជធានី ភ្នំពេញ
Tel/Fax : (855) 23 224 120; E-mail : csc@catholiccambodia.org; Website: www.catholiccambodia.org
ក្រុមប្រឹក្សាភិបាល : លោកអភិបាល អេមីល ដេតម្ប និងលោកអូមែរ ហ្ស៊ីរ៉ាល់ដូ ។ ចាងហ្វាងការផ្សាយ : លោកលី សុវណ្ណា ។ រោងពុម្ព : ភ្នំពេញ។